# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៦ ខែមេសា លេខ ៤

ព.ស. ២៤៩៧ – គ.ស. ១៩៥៤

# សេចក្ដីថ្លែងអំណរគុណ

កាលពីថ្ងៃ អង្គារ ១៣ កើតខែផល្គុន ( ១៦ មីនា ) គ.ស. ១៩៥៤ នេះ អ្នកស្រី ម៉ិះក្រេង គ្រូបង្ហាត់ល្ខោនព្រះរាជទ្រព្យ ព្រមទាំងអ្នកស្រី ក្តាំងងារ ជាប្អូន ទីលំនៅនៅភូមិបឹងកេងកង សង្កាត់លេខ ៦ ក្រុងភ្នំពេញ មានចិត្តសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា យល់ច្បាស់នូវអានិសង្សនៃសាធារណប្រយោជន៍ បានធ្វើអំណោយគម្ពីរ សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកបាឋ បាលីសុទ្ធជាគម្ពីរស្លឹករឹត ចបមាសយ៉ាងល្អ ១ គម្ពីរ ចំនួន ១៩ ខ្សែ ដល់ពុទ្ធសាសនបណ្ឌិត្យ ដើម្បីដំកល់ទុកនៅមន្ទីរនេះ សម្រាប់ជាប្រយោជន៍សាធារណ៍ ដល់ពួកសិក្ខាកាមកុលបុត្រក្នុងព្រះពុទ្ធសាសនាទូទៅ ។

ពុទ្ធសាសនបណ្ឌិត្យ បានទទួលគម្ពីរនេះចុះបញ្ជីទុកជាសម្បត្តិរបស់ក្រសួងតទៅ ហើយសូមសរសើរនូវកាយវិការដ៏ថ្លៃថ្លារបស់អ្នកស្រីម៉ិះក្រេង និងអ្នកស្រីក្តាំងងារ ព្រមទាំងសូមថ្លែងអំណរគុណយ៉ាង

ជូន ....

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

របោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| — ពហុបការធម៌ | ព្រះមហា ជា - ឆាយ | ២៤៣ |
| — វម្មិកប្បញ្ហា ( តចប់ ) | ព្រះមហា ច័ន្ទ - ហុង | ២៥៤ |
| — បញ្ញាសជាតក ភាគទី ២ | បណ្ឌិតមហា ឈឹម - ស៊ុម | ២៦២ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| — ការបណ្ដុះនិស្ស័យ (តចប់) | ព្រះមហាឧត្តមវិជ្ជា ប៊ឹង - ប៉ម | ២៨២ |
| — រឿងសាមកុក (តមក) | ឧកញ៉ា នូ - កន | ២៩១ |
| — ទាលះនឹងទមយន្តី (តមក) | អ្នកស្រី ស៊្រុន - សារីយ៉ាន់ | ២៩៨ |
| — ដំណើរអស្ចារ្យនៃលោកភីសូប៊ីយូយេ (តមក) | លោកវ៉ាយ - ប៊ុក | ៣០៤ |
| — ដំណឹងតាមខ្យល់ក្នុងកន្ទារៈ (តមក) | លោកផេង - ជ្រីវ | ៣០៩ |
| **កំណត់ទីនប្រវត្តិការណ៍** | | |
| — សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ បរិយាយពីវិធាននៃក្រុមជំនុំ | លោក ចាប - ពិន | ៣១៤ |
| — សមណសក្តិនៃព្រះសង្ឃ ១៣ រូប | ពុទ្ធសាសនបណ្ឌិត្យ | ៣១៨ |



មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES

### PARTIE RELIGIEUSE:


— Bahupakaradharma . . . . . *Brah Maha* CHEA-CHHAY . . . 243

— Vammikappanha (suite et fin) . *Brah Maha* CHANN-HONG . . 254

— Pannasajataka-vol.II . . . . . M. CHHIM-SOUM . . . . . . 262


### PARTIE LITTERAIRE:


— Education morale (suite et fin) *Brah Maha* PEUNG-PAM . . . . 282

— Histoire de SAMKOK (suite) . *Oknha* NOU-KAN . . . . . . . 291

— Nala et Damayanti (suite) . . *Mme* SRIN-SARIS-YANN . . . . 298

— Le voyage extraordinaire de Vasiobioyé (suite) . . . . . . M. RAY-BUC . . . . . . . . . . 304

— Le souffle du désert (suite) . M. PHENG CHRIV . . . . . . . 309


### NOTES ET CHRONIQUES:


— Activité de la Commission des Moeurs et Coutumes. . . . . M. CHAP-PIN . . . . . . . . . 314

— Avancement en grade de 13 dignitaires religieux . . . . . *Institut - Bouddhique* . . . . . 318


Prix d'abonnement annuel ( comprenant 12 numéros) 200$00

ពហុបការធម៌

# ព្រះមហា ជា-ឆាយ វិត្ថុណ្ណាលោម

រៀបរៀង

---

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*សូមនមស្ការចំពោះព្រះភគវន្តមុនី អរហំសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ) ។*

*ពេលនេះជាធម្មស្សវនកាល ត្រូវតាមសណ្ដាប់ប្រវេណីពីបុរាណសម័យ នៃពុទ្ធសាសនិកជនរៀងរាបមក ។ អាត្មាភាពបានទទួលភារៈមកសំដែងធម៌ទេសនា តាមសមគួរដល់កាលវេលា, ឱកាសនេះសូមសំដែងអំពីពហុបការធម៌ តាមន័យព្រះពុទ្ធភាសិត ក្នុងសុត្តន្តបិដកទសុត្តរសូត្រ ត្ថមីទេឃនិកាយ ដូចមានបទព្រះបាលីថា*

ឯកោ ធម្មោ ពហុបការោ អប្បមាទោ កុសលេសុ ធម្មេសុ, អយំ ឯកោ ធម្មោ ពហុបការោ *ប្រែថា "ធម៌មួយមានឧបការៈច្រើន គឺ អប្បមាទ (ការមិនធ្វេសប្រហែស) ក្នុងធម៌ទាំងឡាយជាកុសល, នេះហៅថា ធម៌មួយ មានឧបការៈច្រើន" ។*

*អាត្មាភាពសូមអធិប្បាយតាមន័យព្រះពុទ្ធដីកាខាងលើ ដូចសេចក្ដីតទៅនេះ :*

អប្បមាទ ប្រែថា សេចក្ដីមិនធ្វេសប្រហែស, ការមិនធ្វេសស្មារតី ឬការប្រុងប្រយ័ត្នមិនឲ្យភ្លាំងភ្លាត់ ។ សេចក្ដីមិនប្រហែសធ្វេសនេះជាធម៌ចំបងជាងកុសលធម៌ទាំងពួង ឬថាកុសលធម៌ទាំងពួងមានអប្បមាទជាឫស សមដូចព្រះពុទ្ធដីកាថា យេ កេចិ កុសលា ធម្មា សព្វេ តេ អប្បមាទមូលកា អប្បមាទសមោសរណា អប្បមាទោ តេសំ អគ្គមក្ខាយតិ ប្រែថា "ធម៌ទាំងឡាយណានីមួយដែលជាកុសល, ធម៌ទាំងអស់នោះ មានសេចក្ដីមិនប្រមាទជាឫស គឺជាឫសគល់ប្រជុំចុះក្នុងសេចក្ដីមិនប្រមាទទាំងអស់ ; អ្នកប្រាជ្ញទាំងឡាយតែងពោលសរសើរសេចក្ដីមិនប្រមាទថា ជាធម៌ចំបងជាងកុសលធម៌ទាំងនោះ" ។

សេចក្ដីមិនប្រមាទនេះ អ្នកប្រាជ្ញពោលថាជាចំបង ឬជាកំពូលនៃកុសលធម៌នោះ ព្រោះកុសលធម៌ទាំងអស់ដែលនឹងកើតឡើងបានក៏ព្រោះតែសេចក្ដីមិនប្រមាទកើតឡើងជាមុន ឬថាលុះណាតែអប្បមាទធម៌កើតឡើងមុន ទើបកុសលធម៌ឯទៀតៗកើតឡើងបាន ដូចមេដំបូលផ្ទះ ជាទីប្រជុំចុះនៃទព្វសម្ភារៈ មានផ្ដៅផ្ទានជាដើម ។ ព្រោះហេតុនោះ ព្រះបរមគ្រូទ្រង់ត្រាស់សំដែងថា នាហំ ភិក្ខវេ អញ្ញំ ឯកធម្មំ សមនុបស្សាមិ "ម្នាលភិក្ខុទាំងឡាយ! តថាគតជញ្ជឹងរំពឹងមើលទៅមិនឃើញមានធម៌ដទៃណា ដែលជាធម៌មានអានុភាពអាចញុំាងកុសល

ដែលមិនទាន់កើតឡើងឲ្យកើតឡើង, ដែលកើតឡើងហើយឲ្យរឹងរឹតតែចំរើនឡើង ដូចជាសេចក្ដីមិនប្រមាទនេះឡើយ" ។ ម្យ៉ាងទៀត សេចក្ដីមិនប្រមាទនេះ បើនឹងពោលតាមបរិយាយ គឺគឺសតិហ្នឹងឯង. សតិនឹងអប្បមាទ មានសេចក្ដីជាមួយគ្នា សមដូចព្រះពុទ្ធដីកាថា ចតូសុ ភិក្ខវេ ឋានេសុ អត្តរូបេន អប្បមាទោ សតិ ចេតសោ អារក្ខោ ករណីយោ ប្រែថា "ម្នាលភិក្ខុទាំងឡាយ ! សេចក្ដីមិនប្រមាទ គឺសតិជាធម៌រក្សានូវចិត្ត ជាធម៌ដែលអ្នកពល់គ្នាត្រូវធ្វើក្នុងស្ថាន ៤ យ៉ាង តាមសមគួរដល់ខ្លួន ។ ឯសេចក្ដីមិនប្រមាទដែលអ្នកទាំងឡាយត្រូវធ្វើក្នុងស្ថាន ៤ យ៉ាងនោះ គឺត្រូវតាំងចិត្តថា:

១ ចិត្តរបស់អាត្មាអញ កុំត្រេកត្រអាលក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្ដីត្រេកត្រអាល;

២ – ចិត្តរបស់អាត្មាអញ កុំប្រទូស្តក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្ដីប្រទូស្ត;

៣ – ចិត្តរបស់អាត្មាអញ កុំវង្វេងក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្ដីវង្វេង;

៤ – ចិត្តរបស់អាត្មាអញ កុំស្រវឹងក្នុងធម៌ដែលជាហេតុឲ្យកើតសេចក្ដីស្រវឹងឡើយ ។

ន័យមួយទៀត សេចក្ដីមិនប្រមាទនេះ បើពោលដោយការប្រតិបត្តិ ដែលជាការទំនុកបំរុងផ្ចុងផ្ដើមក៏បានខាងមនសិការៈ គឺការយកចិត្តទុកដាក់ ក្នុងខយវយធម៌ គឺរំពឹងដល់សេចក្ដីអស់ទៅទឹងសូន្យទៅ ៗ មែនពិត, បុគ្គលនឹករំពឹងដល់សេចក្ដីអស់ទៅទឹងសូន្យទៅនៃសង្ខារ ដោយអំណាច នៃការចាស់ ឈឺ ស្លាប់ក្ដី នឹករំពឹងដញ្ជឹងថា ឱសេចក្ដីចាស់ ឈឺ ស្លាប់ផ្ទាត់ ជាភ័យធំរបស់សត្វនិករចេះតែរុករានទន្ទ្រានចូលមកកាន់តែ ជិត ៗ ណាស់ហើយ ដូច្នេះក្ដី, ត្រិះរិះពិចារណា នូវអភិណ្ហប្បច្ចវេក្ខណធម៌ មានដើមថា ការចាស់គ្រាំគ្រាជាធម្មតានឹងកន្លងការចាស់គ្រាំគ្រាទៅ មិនបានឡើយដូច្នេះក្ដី កាលបើពិចារណាក្នុងអភិណ្ហប្បច្ចវេក្ខណៈយ៉ាង នេះជាដើមហើយ តពីនោះទៅទើបមិនប្រមាទ ហើយខំខ្មីឃ្មាតបំពេញ ករណីយកិច្ចរបស់ខ្លួន ឲ្យចំរើនកើតមានឡើង ៗ ការពិចារណានេះ ជាឧបាយដើម្បីបំបាត់នូវសេចក្ដីប្រមាទសេចក្ដីស្រវឹងថា អាត្មាអញនៅ កម្លោះក្រមុំ ថាមិនមានរោគ មិនទាន់ស្លាប់ ទាំងជាឧបាយដើម្បីរំកិល ខ្លួនឲ្យផុតចាកបាប បែរមុខឆ្ពោះទៅរកបុណ្យកុសលតែម្យ៉ាង ៗ ឯឧបាយ សម្រាប់រំពឹងពិចារណាឲ្យឃើញសេចក្ដីអស់ទៅទឹងសូន្យទៅ ដែលជា ហេតុនាំឲ្យកើតអប្បមាទធម៌នោះមានច្រើនប្រការណាស់, អ្នកប្រាជ្ញបាន នាំយកធម៌ទាំងឡាយ ដែលជាហេតុឲ្យកើតអប្បមាទធម៌ ហៅថា វិបស្សនា មកឲ្យពិចារណាថា “រូបទាំងអតីត អនាគត បច្ចុប្បន្ន ដែល

អាស្រ័យបច្ច័យតាក់តែងហើយកើតឡើង ជារបស់មិនទៀង មានកិរិយា
អស់ទៅសូន្យទៅ ប្រែប្រួលទៅ រលត់ទៅជាធម្មតា; ទាំងវេទនា សញ្ញា
សង្ខារ វិញ្ញាណ ក៏ដូចគ្នាដែរ ។ សេចក្តីទៀង សេចក្តីសុខសប្បាយ
រីករាយត្រេកត្រអាលអរសាទរនឹងមានមកពីណា? ព្រោះថារបស់ណា
ដែលកើតឡើងហើយ សុទ្ធតែត្រូវវិនាសបែកធ្លាយទៅវិញទាំងអស់;
ទ្រព្យសម្បត្តិរបស់អាត្មាអញក្តី ជីវិតរបស់អាត្មាអញក្តី នឹងវិនាស
ព្រាត់ប្រាសទៅមិនខាន; ទោះសព្វសត្វក្នុងត្រៃភព ក៏ត្រូវវិនាសព្រាត់
ប្រាសដូចគ្នាទាំងអស់ដែរ ព្រោះការព្រាត់ប្រាសចាកសត្វនិងសង្ខារនេះ
ជាធម៌សម្រាប់ជនទូទៅ ។ ទៈ ថ្ងៃនឹងយប់ចេះតែកន្លងទៅហើយ
អាយុរបស់អាត្មាអញក៏អស់ទៅ តាមថ្ងៃនឹងយប់ដែលកន្លងទៅនោះដែរ
បច្ច័យនៃសេចក្តីស្លាប់របស់អាត្មាអញមានច្រើនក្រៃពេក ,មានទាំងខាង
ក្នុងទាំងខាងក្រៅ អាត្មាអញមុខជានឹងធ្វើកាលកិរិយាដោយហេតុនោះៗ
ដោយអន្តរាយនោះៗ មិនខានឡើយ" ។ កាលបើបានពិចារណា
តាមន័យនេះហើយ ក៏ជាឧបាយឲ្យកើតអប្បមាទធម៌ទាំងអស់ ។ កាល
បើអប្បមាទធម៌កើតឡើងហើយ, បណ្ឌិតគួរស្ងួនគ្រងរក្សាថែទាំអប្បមាទ-
ធម៌នោះ ដូចជាបុគ្គលសំឡឹងឃើញនូវប្រយោជន៍នៃទ្រព្យ ហើយខំ
ថែរក្សាទ្រព្យមិនឲ្យអន្តរាយដូច្នោះ ព្រោះអប្បមាទធម៌នេះ ព្រះសម្ពុទ្ធ
ជាម្ចាស់ទ្រង់ត្រាស់ថា មានឧបការៈច្រើនណាស់ ជាកំពូលនៃធម៌ជា

កុសលឯទៀត ៗ ។ ព្រោះហេតុតែអប្បមាទធម៌ ជាធម៌មានឧបការៈច្រើន ជាធម៌ចំបងជាងធម៌ជាកុសលទាំងពួង ឬថាជាមាតាបិតានៃសេចក្តីសុខចំរើនទូទៅពិតប្រាកដមែនហើយ បានជាព្រះបរមគ្រូ សូម្បីតែទ្រង់ហៀបនឹងរំលត់ខន្ធចូលកាន់បរមនិព្វានហើយ ទ្រង់បែរព្រះភក្ត្រឈមទៅរកភិក្ខុបរិស័ទ ដែលអង្គុយគាល់ព័ទ្ធជុំវិញព្រះអង្គ ទ្រង់មានព្រះពុទ្ធដីកាផ្តាំថា ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ, វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ "ម្នាលភិក្ខុទាំងឡាយ ! ឥឡូវនេះតថាគតផ្តាំនូវអ្នកពល់គ្នា សង្ខារទាំងឡាយមានការសូន្យទៅជាធម្មតា. អ្នកពល់គ្នាចូរញ៉ាំងប្រយោជន៍ឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ" ។ ឥទំ បច្ឆិមពុទ្ធវចនំ នេះជាព្រះពុទ្ធដីកាប្រៀនប្រដៅពៅបំផុតនៃព្រះពុទ្ធជាម្ចាស់ ។

សេចក្តីមិនប្រមាទនេះ មានទំនងគួរនឹងអធិប្បាយបានច្រើនជាអនេក ដូចជាសេចក្តីមិនប្រមាទក្នុងការថែទាំរក្សាខ្លួន ក្នុងវ័យទាំងបីវ័យណាមួយ, មិនប្រមាទក្នុងការរៀនសូត្របំណេះវិជ្ជាផ្សេង ៗ, មិនប្រមាទក្នុងការសំដែង, មិនប្រមាទក្នុងការស្វែងរកទ្រព្យសម្បត្តិ, មិនប្រមាទក្នុងការសន្សំកុសលជាដើម ទាំងនេះក៏គួរឃើញថាសេចក្តីមិនប្រមាទនេះ ជាប្រធានលើកិច្ចការគ្រប់ជំពូក ៗ

សេចក្ដីមិនប្រមាទ  ពិតមែនតែមានន័យច្រើនយ៉ាង  តែបើរួមឲ្យខ្លីទៅមានតែត្រឹមពីរយ៉ាង  គឺៈ

១ – មិនប្រមាទក្នុងការលះ

២ – មិនប្រមាទក្នុងការចំរើន

លំដាប់ពីនេះ អាត្មាភាពសូមអធិប្បាយនូវសេចក្ដីមិនប្រមាទទាំងពីរយ៉ាងនេះ  ដូចតទៅនេះ ៖

## មិនប្រមាទក្នុងការលះ

បាបកម្ម  គឺអំពើដ៏លាមក  អំពើដែលជាហេតុញុំាងសត្វឲ្យទៅកើតក្នុងចតុរាបាយ  អំពើដែលញុំាងសត្វឲ្យក្ដៅក្រហាយស្ដាយក្រោយ  ព្រោះតែការរងទុក្ខលំបាកក្នុងទុគ្គតិ  បុគ្គលគួរលះបង់  គួរវៀរតមកុំធ្វើ  ព្រោះជាអំពើនាំឲ្យវិនាសខ្លួន ។  អកុសលមូលគឺឫសគល់នៃអកុសលធម៌ទាំង ៣ ប្រការគឺលោភៈ ទោសៈ មោហៈ បុគ្គលគួរតែលះបង់ ព្រោះអកុសលមូលទាំង ៣ នេះ  ជាតួបាបផង  ជាមូលហេតុគឺជាដើមចមនាំឲ្យធ្វើអំពើបាបផង ។  បញ្ចវេរគឺអំពើ ៥ យ៉ាងដែលបុគ្គលធ្វើហើយនាំឲ្យមានពៀរវេរ គឺការសម្លាប់សត្វដែលមានជីវិតមិនកំណត់ថាប្រុសស្រីចាស់ក្មេង  ទោះបីសត្វតូចល្អិតៗ ឬសត្វនៅក្នុងគភ៌;  ការលួចទ្រព្យដែលគេមិនបានឲ្យ ទោះបីថោកថ្លៃ តិចច្រើនក៏ដោយ  ឬទ្រព្យដែលគេឧទ្ទិសបូជាចំពោះសង្ឃ ឬក៏ចំពោះសាសនា;  ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ  គឺកិរិយា

ស្រឡាញ់ក្លួចកាន់ ឬប្រាថ្នាកន្លួរប្រវេណី ដែលមិនត្រូវប្រាថ្នា មិនត្រូវប្រព្រឹត្តជាហេតុឲ្យសៅហ្មង មានគំនុំគុំគួននឹងគ្នារវាងត្រកូលទូទៅ; ការកុហក គឺការនិយាយបំភ័ន្តអ្នកស្តាប់ឲ្យចូលចិត្តខុស ឲ្យយល់ខុស ឲ្យយល់ឃ្លាងចាកគន្លងធម៌; ការផឹកសុរានឹងមេរ័យ គឺទឹកដែលកើតមកអំពីគ្រឿងត្រាំផ្លែឈើ ឬធញ្ញជាតិផ្សេងៗ គេត្រាំទុកយូរពាល់តែជូរផ្អមខ្លាំងក្លាយរសជាតិទៅជាស្រវឹងក្តី គេយកធញ្ញជាតិស្ងោរម្ទាស់ចិទចំហុយយកតំណក់ញើសនោះក្តី ធ្វើដោយបែបផ្សេងៗទៀតក្តី ទឹកតម្រាំ ដែលគេដាក់មេជាតិស្រវឹងត្រាំទុកឲ្យចេញរសជាតិ ដូចទឹកត្នោតជូរជាដើមក្តី ពោះបីខ្លាំងក្តី ខ្សោយក្តីជាទឹកស្រវឹងជាទីតាំងនៃសេចក្តីប្រមាទ ។ ទាំង ៥ នេះហៅថាបញ្ចវេរ បុគ្គលគួរលះបង់ គួរវៀរតមកុំធ្វើ ព្រោះសុទ្ធតែជាអំពើនាំឲ្យមានទោសទុក្ខច្រើនប្រការក្នុងលោកនេះ នឹងបរលោក ដូចជាជាប់គុកច្រវាក់ វាយដំប្រដាក់ស្មើរតែក្ស័យប្រាណ ឬកំកើតជាជម្លោះទាស់ទែងខ្វែងគំនិតគ្នា នាំឲ្យមានទោសទុក្ខច្រើនប្រការទៀតជាដើម ឯបព្វជិតគឺអ្នកបួសវិញ ក៏ត្រូវលះអំពើដែលទំនាស់ទាស់ខុសនឹងវិន័យសិក្ខាដូចជាអនេសនៈ បាបធម៌ វេជ្ជកម្ម ទូតកម្ម កុលទូសកកម្ម នឹងអនាចារផ្សេងៗ ជាដើមពោលចេញដែរ ។ មែនពិត, គេទបព្វជិតនេះ ជាគេទឧត្តមវិសេសបែកជាងគេទគ្រហស្ថ ត្រូវតែឲ្យមានអប្បមាទធម៌ជានិច្ចដើម្បីបំពេញកិច្ចវត្តផ្សេងៗ ឲ្យបានបរិបូណ៌, មិនត្រូវបណ្តែតបណ្តោយ

ធ្វេសប្រហែសក្តេចខ្លួនឡើយ ត្រូវតែជាអ្នកតាំងនៅក្នុងសីល ជាគ្រឿងរក្សាកាយវាចាឲ្យមានសណ្ដាប់ធ្នាប់ ឲ្យមានឥន្ទ្រិយស្រគត់ស្រគំសមរម ល្អត្រេកអរក្នុងករណីយកិច្ចរបស់ខ្លួន ជាអ្នក ឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច ប្រតិបត្តិមានទំនងនឹងរើខ្លួនឲ្យរួចចាកទុក្ខ គួរឲ្យជាទីជ្រះថ្លា, មិនត្រូវប្រហែសបណ្ដែតបណ្ដោយ ធ្លោយគំនិតឲ្យបាបធម៌ញាំញីសង្កត់សង្កិនចិត្ត ហើយប្រព្រឹត្តប្រទូស្តបៀតបៀនអ្នកដទៃឡើយ ។ បព្វជិតណា ដែលមិនអើពើនឹងវិន័យសិក្ខា មានអាការកិរិយាប្រព្រឹត្តប្រឡេសបើសឃ្លើសឃ្លងប្រឡោងខាម ខុសខ្នាតវិន័យ បព្វជិតនោះមិនសមស័ក្តិជាភិក្ខុ ឬជាសមណសក្យបុត្រឡើយ លុះតែបព្វជិតណាដែលសង្រួមកាយ វាចា ដោយល្អតាមវិន័យ សេក្ខិយវត្ត ដែលព្រះសុគតប្រញ័ត្តិទុកមក មានចិត្តស្ងប់រម្ងាប់ចាកបាបអកុសល បព្វជិតនោះ ទើបគួរដល់ឋានៈជាភិក្ខុជាសមណសក្យបុត្រពិតប្រាកដមែន ។ ម្យ៉ាងទៀត កិច្ចការណា ៗ ដែលប្រព្រឹត្តទៅ ដើម្បីខូចប្រយោជន៍ខ្លួននិងអ្នកដទៃនោះ ៗ ជាអំពើគួរលះឲ្យស្រឡះចេញ ទោះបីបន្តិចបន្តួចស្តួចស្តើងយ៉ាងកិច្ចការណា ក៏មិនគួរប្រថុយធ្វើដែរ ។ ដែលអធិប្បាយមកនេះក្នុងសេចក្តីមិនប្រមាទក្នុងការលះ ។

## មិនប្រមាទក្នុងការចម្រើន

កុសលកម្ម គឺអំពើដែលកំចាត់បង់នូវសេចក្តីអាក្រក់ទូទៅ ជាកម្មអាចញ៉ាំងសត្វឲ្យដល់នូវសុគតិ ជាអំពើគួរធ្វើគួរចម្រើនឲ្យកើតមាន ។

និច្ចសីល គឺជាសីលដែលគួរប្រព្រឹត្តកាន់រក្សាឲ្យទៀងទាត់អស់កាលជានិច្ចមិនកំណត់កាលវេលា ។ ឧបោសថសីល ជាសីលគួរសមាទានរក្សាតាមកាលកំណត់ ។ ធម្មចរិយា គឺការប្រព្រឹត្តល្អដោយកាយវាចាចិត្ត សម្រាប់បណ្តុះសេចក្តីចំរើន ទប់ទល់នឹងសេចក្តីវិនាសទាំងអស់ គ្រហស្ថគួរចំរើនឲ្យកើតមានឡើង ។ ចតុប្បារិសុទ្ធសីល នឹងកិច្ចវត្តឯទៀត ៗ ដូចយ៉ាងអភិសមាចារិកវត្ត សេក្ខិយវត្ត, ឧបជ្ឈាយវត្ត ជាដើម បព្វជិតត្រូវប្រព្រឹត្ត ដើម្បីឲ្យមានសណ្តាប់ធ្នាប់សមរម្យជាភិក្ខុសាមណេរក្នុងពុទ្ធសាសនាតទៅ ។

ម្យ៉ាងទៀត អំពើណា ៗ ដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ដើម្បីសេចក្តីសុខ ចំរើន ដល់ខ្លួននិងអ្នកដទៃ អំពើនោះៗ ជាអំពើគួរចំរើន ទោះបីតិចតួចក៏មិនគួរប្រមាទដែរ គួរតែចំរើនឲ្យកើតច្រើនឡើងដោយលំដាប់កុំខាន ។ នេះជាសេចក្តីមិនប្រមាទក្នុងការចំរើន ។

រួបរួមសេចក្តីដែលបានអធិប្បាយមកនេះ ឈ្មោះថាអប្បមាទធម៌ ជាធម៌មានឧបការៈច្រើនជាងកុសលធម៌ទាំងអស់ ។ ធម៌នេះសប្បុរសទាំងឡាយគួរស្ងួនគ្រងរក្សាទុក ជាធម៌តែមួយទេ តែមានឧបការៈច្រើនសមដូចពុទ្ធភាសិតដែលពោលមកក្នុងខាងដើម ។

អាត្មាភាព សំដែងធម៌មកនេះសមគួរដល់កាលវេលាតែប៉ុណ្ណោះ ឯវំ ។

យំ យម្បិ បត្ថិតំ តុយ្ហំ តំ តំ សព្វំ សមិជ្ឈតុ
ឥមិនា ធម្មទានេន សុខិតា ហោថ សាធវោ

សេចក្តីប្រាថ្នាណាៗ ដែលពុទ្ធបរិស័ទប្រាថ្នាហើយ សេចក្តីប្រាថ្នានោះៗ ទាំងអស់ សូមឲ្យបានសម្រេចកុំបីខាន! ដោយអំណាចនៃធម្មទាននេះ សូមឲ្យពុទ្ធបរិស័ទទាំងឡាយបានសេចក្តីសុខគ្រប់ប្រការ កុំបីឃ្លាត!

រតនត្តយតេជេន កម្ពោជរដ្ឋវាសិនោ
វុឌ្ឍិំ វិរុឡ្ហិំ បប្បោន្តុ សន្តិភាវញ្ច នាញ្ញថា

ដោយតេជៈនៃព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ សូមឲ្យប្រជាជនទាំងឡាយ អ្នកនៅក្នុងកម្ពុជរដ្ឋ បាននូវសេចក្តីចម្រើន លូតលាស់និងសន្តិភាព កុំបីឃ្លាតក្លាយទៅជាប្រការដទៃឡើយ! ។

---

ធម្មកាបញ្ញា

ព្រះមហា ប័ន្ធ-ហុង

វត្តបល្ល័ង្ក ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង

រៀបរៀង

(ត - បត)

---

## ប្រយោជន៍ក្នុងបរលោកមាន ៤ យ៉ាង

១.— សទ្ធាសម្បទា បរិបូណ៌ដោយសទ្ធាគឺការជឿជាក់ចំពោះគុណព្រះរតនត្រ័យ ដែលជាកែវដ៏វិសេសវិសាលត្រកាលជាន់សវិញ្ញាណករតនៈនិងអវិញ្ញាណករតនៈ ៗ ក្នុងភពទាំងបី(១) ឥតមានវត្ថុអ្វីសម្រាប់បំភ្លឺបានទេ, លោកទាំងមូលដែលអាចនឹងភ្លឺស្វាងរុងរឿងកំចាត់អវិជ្ជាទៅបាន ក៏ព្រោះតែគុណព្រះរតនត្រ័យ ដ៏មានសិរីតេជានុភាព ៗ

### សទ្ធានោះមាន ៤ យ៉ាង គឺ

ក) កម្មសទ្ធា ជឿកម្ម

ខ) វិបាកសទ្ធា ជឿផលរបស់កម្ម

គ) កម្មស្សកតាសទ្ធា ជឿថាសត្វមានកម្មជារបស់ខ្លួន

---

១ គឺកាមភព, រូបភព, អរូបភព ។

ឃ) តថាគតពោធិសទ្ធា ជឿបញ្ញាត្រាស់ដឹងរបស់ព្រះតថាគត ។

បើធ្វើល្អ ផលដែលហុចឲ្យមកវិញក៏ល្អ, ធ្វើអាក្រក់ ផលដែលហុចឲ្យមកវិញក៏អាក្រក់, បើធ្វើទាំងកម្មល្អផងអាក្រក់ផង ផលដែលហុចឲ្យមកវិញក៏បានទាំងអាក្រក់ទាំងល្អ ។ សមដូចសុភាសិតថា

យាទិសំ លភតេ ពីជំ តាទិសំ លភតេ ផលំ
កល្យាណការី កល្យាណំ បាបការី ច បាបកំ

ប្រែថា "បុគ្គលសាបព្រោះពូជបែបណា រមែងបានផលបែបនោះ បុគ្គលធ្វើទាំងកម្មល្អតែងបានផលល្អ បុគ្គលធ្វើទាំងអំពើអាក្រក់តែងបានផលអាក្រក់" ។

## លក្ខណៈរបស់សទ្ធាមាន ៤ យ៉ាងគឺ

ក) សទ្ធាមានសេចក្តីជឿជាលក្ខណៈ

ខ) សទ្ធាមានសេចក្តីជ្រះថ្លាជាលក្ខណៈ

គ) សទ្ធាមានកិរិយាលឿនទៅ ឬស្ទុះស្ទាទៅជាលក្ខណៈ

ឃ) សទ្ធាមានកិរិយាតាំងមាំ ក្នុងវត្ថុដែលគួរជឿជាលក្ខណៈ ។

លក្ខណៈទាំង ៤ យ៉ាងនេះ ជាគ្រឿងសំគាល់របស់សទ្ធា ឲ្យដឹងថា ជឿឬមិនជឿ, ជ្រះថ្លាឬមិនជ្រះថ្លា, មានកំឡាំងអាចស្ទុះស្ទាលឿនទៅ

ដែរឬគ្មាន, មានកិរិយាតាំងមាំស៊ប់សួនកង់រគ្នាដែរឬគ្មាន យ៉ាងនេះ ហៅថា ប្រដាប់សម្រាប់សង្កេតឲ្យបំណាំចាំជាក់នូវសទ្ធា ។

ម្យ៉ាងទៀត សទ្ធានេះអាចឆ្លងនូវអន្លង់បានដោយពិត ដូចសុភាសិតថា សទ្ធាយ តរតិ ឱឃំ គេឆ្លងនូវអន្លង់ ដោយសទ្ធា ។

## អន្លង់ ៤ យ៉ាង គឺ

ក ) អន្លង់គឺកាមគុណប្រាំ

ខ ) អន្លង់គឺភព

គ ) អន្លង់គឺទិដ្ឋិ

ឃ) អន្លង់គឺអវិជ្ជា ។

២.— សីលសម្បទា បរិបូណ៌ដោយការរក្សាសីល ។ សីលនោះ សម្រាប់គ្រហស្ថបានដល់និច្ចសីល គឺសីលដែលបុរសស្ត្រីរក្សាជានិច្ចមិនកំណត់កាលវេលា ទីងកុសលកម្មបថ ១០ ប្រការ ។

៣.— ចាគសម្បទា បរិបូណ៌ដោយការបរិច្ចាគទ្រព្យសម្បត្តិចាត់ចែងធ្វើបុញ្ញកម្ម មានកសាងកុដិ, សាលា, វិហារ, ជីកអណ្តូង, លើកស្រះ, សង់ស្ពាន, សាងផ្លូវថ្នល់, សង់មន្ទីរពេទ្យសម្រាប់ព្យាបាលរោគជាដើម ។

៤.— បញ្ញាសម្បទា បរិបូណ៌ដោយប្រាជ្ញាការចេះដឹងក្នុងសាសនា ក៏ព្រោះកុសលធម៌ទាំងពួង, ប៉ុកច្បាក់ផ្ទះបំពោះទៅបរមត្ថសុខ ។

## អ្នកណាជាព្រាហ្មណ៍?

ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ដែលប្រកបដោយមហាបុរិសលក្ខណៈទាំង ៣២ ប្រការ[1] ហៅថាព្រាហ្មណ៍ ។

## អ្នកណាជាសុមេធ?

ភិក្ខុជាសេក្ខបុគ្គលអ្នកប្រកបក្នុងការរៀនមាន ៧ ជំពូក មានសោតាបត្តិមគ្គជាដើម មានអរហត្តមគ្គជាបរិយោសាន ហៅថាសុមេធ ។

## អ្វីជាសុស្ត្រា?

ប្រាជ្ញាដ៏ប្រសើរ ហៅថា សុស្ត្រា ។ បញ្ញានេះមានច្រើនប្រភេទណាស់, តែក្នុងទីនេះសូមដកស្រង់យកបញ្ញា ៤ យ៉ាង គឺ

១.— ទុក្ខេ ញាណំ ប្រាជ្ញាដឹងទុក្ខទាំង ១២ កង មានជាតិទុក្ខជាដើម មានយម្បិច្ឆំ ន លភតិ តម្បិទុក្ខំ ជាទីបំផុត ។

---

១ ចូរមើលលក្ខណសូត្រ ទីឃនិកាយ បាដិកវគ្គ, និងព្រហ្មាយុសូត្រ មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកឯណោះ ។

គំប៉ុន្តែទុក្ខទាំងអស់នេះបើប្រមូលឲ្យខ្លីចុះមកមានត្រឹមតែ ៥ យ៉ាងប៉ុណ្ណោះគឺ រូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។

ព្រះសយម្ភូញាណ ទ្រង់សំដែងថា "បើនៅមានខន្ធដរាបណា ដរាបនោះឈ្មោះថាប្រកបដោយទុក្ខ" បើមិនមានខន្ធទេ សេចក្ដីយំសោកបោកប្រាណទុក្ខទោមនស្សក៏មិនមានដែរ, យ៉ាងនេះហៅថាបញ្ញាដឹងកង់កងទុក្ខ ។

២.— ទុក្ខសមុទយេ ញាណំ ប្រាជ្ញាដឹងកង់ហេតុដែលនាំបណ្ដាលឲ្យកើតទុក្ខ មកពីតណ្ហាទាំង ៣ ឬ ១០៨ ។

៣.— ទុក្ខនិរោធេ ញាណំ បញ្ញាដឹងនូវកន្លែងរំលត់ទុក្ខ គឺព្រះនិព្វាន ។

៤.— ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ ប្រាជ្ញាដឹងនូវផ្លូវប្រតិបត្តិទៅកាន់សេចក្ដីរំលត់ទុក្ខទាំង ១២ កង់ ។

## អ្វីជាការដឹក?

សេចក្ដីព្យាយាមឈ្មោះថាជាការដឹក ពាក្យថា ព្យាយាមនេះគឺព្យាយាមញុំាងសាធារណៈប្រយោជន៍ ទាំងបច្ចុប្បន្នទាំងបរលោកឲ្យកើតមានដល់ខ្លួនទាំងអ្នកដទៃ ។

## អ្វីជាសន្ទះទ្វារកង់ ?

សេចក្ដីងងឹតងងល់ល្ងង់ល្ងប់ពុំដឹងច្បាស់នូវសច្ចធម៌ទាំង ៤ ហៅជាគន្លឹះដែក ឬសន្ទះទ្វារកង់ ។

កង់ដែលវិលលឿនទៅមិនបាន ចេះតែរឹងគាំងនោះ ព្រោះតែគន្លឹះដែកឬទ្រនុកដែកចូលទៅកាំងបិទផ្លូវកង់មិនឲ្យវិល យ៉ាងណា, ពពួកសត្វក្នុងលោកដែលប្រកបដោយអវិជ្ជាក៏យ៉ាងនោះដែរ ។

## អ្វីជាសត្វហឹង ?

សេចក្ដីក្រោធខឹងប៉ោងឡើង ឈ្មោះថា សត្វហឹង ។ សេចក្ដីក្រោធខឹងនេះជាឈ្មោះរបស់ទោសធម៌ ឬធម៌ឈ្លើន ធម៌មេព្រៃ, ហេតុនោះហើយបានជាព្រះអង្គទ្រង់សំដែងអំពីខន្តីធម៌ ជាតបៈធម៌មួយសម្រាប់ដុតកំដៅបំបាត់បង់ នូវសេចក្ដីក្រោធពិរោធ; បើយើងចង់ឈ្នះសេចក្ដីក្រោធត្រូវតែកុំក្រោធខឹងតប ។

## អ្វីជាផ្លូវបែកជាពីរ ?

សេចក្ដីសង្ស័យដែលបែកកន្ទែកចិត្តជាពីរផ្នែក ឈ្មោះថាផ្លូវបែកជាពីរ ។ ការដែលសង្ស័យមិនដាច់ស្រេចនឹងសម្រេចទៅមិនបានយ៉ាងនេះ

មិនអាចនឹងរកសេចក្ដីសុខចំរើនបានទេ ព្រោះរវល់តែនឹងសេចក្ដីសង្ស័យរកទីបំផុតមិនមាន ។

## អ្វីជាសំពត់តម្រងក្បួង?

នីវរណធម៌ ៥ ជាគ្រឿងផង់ល្អិតម៉ត់ បានឈ្មោះថាតម្រងក្បួង ។

## អ្វីជាអណ្ដើក?

សេចក្ដីប្រកាន់ក្នុងឧបាទានក្ខន្ធទាំង ៥ ហៅថា សត្វអណ្ដើក ។

## អ្វីជាកាំបិតនិងជ្រញ់?

កាមគុណទាំង ៥ ដែលអាស្រ័យគ្នាទៅវិញទៅមកគឺរូប អាស្រ័យនឹងភ្នែកជាដើម ហៅថា កាំបិតនឹងជ្រញ់ ។

## អ្វីជាដុំសាច់?

សេចក្ដីត្រេកត្រេកត្រអាលស្រើបស្រាលចំពោះកាមគុណ ឈ្មោះថា ដុំសាច់ ។

## អ្វីជានាគ?

ព្រះខីណាស្រពដែលលោកលះបង់នូវអាសវៈអស់ពីខន្ធសន្ដានតគ-ជាប់ដាច់ពាក់ ហៅថា នាគ ។

ហេតុនេះគ្រហស្ថទាំងឡាយក្តី បព្វជិតក្តី ដែលបានមើលឬបានរៀនទូរវិមិ្មកបញ្ហានេះ សូមឲ្យសម្រេចតាមបំណងកុំបីឃ្លាតឡើយ ។

វិមិ្មកញ្ហា ប្រស្នាទាំង ១៥ ដែលបានសំដែងមកប៉ុណ្ណោះ សន្មតថាចប់ដោយសង្ខេប ។

សាសនារុងរឿងដោយបរិស័ទ
សច្ចធម៌ នៅបវរ បិតគត់មត់
មិនរលត់ មិនរលុប បាត់បង់ទៅ
ដោយបរិសទ្យ ទាំង ៤ ទិស ឲ្យតាំងនៅ
កាន់ត្រឹមត្រូវ មិនខុសផ្លូវ ពីខ្នាត ។
ដែលវិនាស ឬខ្លាតខ្លាយ អន្តរាយបង់
នេះក៏លង់ កងបរិសទ្យ កាន់មិនស្អាត
ទាំងចំរើន ឬវិនាស ពាក្យខ្នាត
ព្រះខ្លោខ្នាត ក៏បរិសទ្យ ទាំង ៤ ដែរ ។
បទ្ម-ហុង

# បញ្ញាសជាតក

## ភាគទី ២

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ ជាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

---

## អារម្ភកថា

គម្ពីរបញ្ញាសជាតក ច្បាប់ដើមជាភាសាបាលី ពុទ្ធសាសនបណ្ឌិត្យបានស្រាវជ្រាវតាំងពី គ.ស. ១៩៤៩ បានសុំសម្ដេចព្រះធម្មលិខិត លី-ឯម, ព្រះឧត្តមមុនី អ៊ុំ-ស៊ូរ និងព្រះញាណវីរិយៈ ឡុង ឲ្យប្រែជាសេចក្ដីសម្រាយបានភាគទី ១ មានចំនួន ៥ រឿង ហើយបោះពុម្ពបញ្ចូលក្នុងទស្សនាវដ្ដី កម្ពុជសុរិយា ជាលើកដំបូងមកម្ដងហើយ លុះមកដល់ គ.ស. ១៩៤៤ បានបោះពុម្ពជាសៀវភៅមួយដោយឡែកម្ដងទៀត ដែលហៅថា បញ្ញាសជាតក ភាគទី ១ (តាំងបាលីតាំងសម្រាយ) ។ សៀវភៅនេះមានជាសេព្វថ្ងៃនៅពុទ្ធសាសនបណ្ឌិត្យ ។

បំណែកខាងជាភាសាបាលី ច្បាប់ដើម ជាគម្ពីរស្លឹករឹត មានអក្សរនិងប្រយោគវិបត្តិច្រើនអន្លើ ៗ កាលពី គ.ស. ១៩៤៣ បណ្ឌិតមហាឈឹម-ស៊ុម កាលនៅជាភេទបព្វជិតបានចម្លងចែកជាភាគៗ បាន ៤ ភាគ ក្នុងមួយភាគៗ មានប្រាំៗ រឿង គឺតាំងពីជាតកទី ១ ដល់ទី ២០, ហើយ

បានផ្ទៀងកែបាលីនិងរបៀបប្រយោគឲ្យត្រឹមត្រូវ ព្រមទាំងបានចាត់ការឲ្យប្រែ ហើយយកមកពិនិត្យកែសម្រួលខាងសម្រាយតាំងពីភាគទី ២ ដល់ភាគទី ៤ ផង ។

ឯគម្ពីរបញ្ញាសជាតក តាំងពីភាគទី ២ តទៅ ពុំទាន់បានបោះពុម្ពផ្សាយនៅឡើយ ។ ហេតុដូច្នេះ យើងយកផ្នែកខាងសម្រាយដែលបណ្ឌិតមហា ឈឹម-ស៊ុម ចាត់ការផ្ញើនោះ មកបោះពុម្ពបញ្ចូលក្នុងទស្សនាវដ្ដី កម្ពុជសុរិយា តាំងពីឆ្នាំ ១៩៥៤ នេះតទៅ ដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទ, ព្រោះគម្ពីរបញ្ញាសជាតកនេះ មានរឿងទាក់ទងដោយគតិធម៌សុទ្ធ ។

---

## វិបុលរាជជាតកទី ៦

(និយាយអំពីពាហិរកទាននឹងអជ្ឈត្តិកទាន)

លោកអាចារ្យ ឈឹម-ណាក ក្រុមជំនុំព្រះត្រៃបិដក

ប្រែពីបាលី

---

ពាហិតសរីរោតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ អត្តនោ ទានបារមឹ អារព្ភ កថេសិ ។

សត្ថា រីអង្គសម្តេចព្រះបរមសាស្ដាចារ្យ កាលទ្រង់គង់សម្រាន្តព្រះឥរិយាបថក្នុងវត្តព្រះជេតពន ក្រុងសាវត្ថី ព្រះជិនស្រីទ្រង់ប្រារព្ធ

នូវការបរិច្ចាគទានរបស់ព្រះអង្គ ទ្រង់ត្រាស់សំដែងព្រះធម៌វិសេស មានបទថាហរិតសរីរោ ដូច្នេះជាដើមបទកំណត់ព្រះគាថា ។

សេចក្ដីដំណាលថា សម័យថ្ងៃមួយ មានភិក្ខុជាច្រើនរូបអង្គុយប្រជុំគ្នាក្នុងរោងធម្មសភា ថ្លែងសរសើរគុណព្រះបរមគ្រូពិជិតមារថា "ម្នាលលោកដ៏មានអាយុទាំងឡាយ, ព្រះតថាគតព្រះអង្គមានបុណ្យច្រើន មានប្រាជ្ញាច្រើន បានបំពេញបារមីមកជាអនេកប្រការ គួរឲ្យអស្ចារ្យក្រៃពេក" ។

គ្រានោះ សម្ដេចព្រះបរមសាស្ដាទ្រង់ព្រះសវនាការព្រះពាក្យនោះដោយទិព្វសោត ទើបទ្រង់ស្ដេចចេញចាកគន្ធកុដិ មកទ្រង់ប្រថាប់នៅលើអាសនៈដ៏ប្រសើរ ហើយទ្រង់មានព្រះពុទ្ធដីកាសួរភិក្ខុទាំងឡាយនោះថា "ម្នាលភិក្ខុទាំងឡាយ, អ្នកទាំងឡាយអង្គុយជជុំគ្នាពីរឿងអ្វី ?" ។ ភិក្ខុទាំងឡាយនោះក្រាបបង្គំទូលថា "បពិត្រព្រះអង្គដ៏ចំរើន, ខ្ញុំព្រះអង្គទាំងឡាយអង្គុយជជុំគ្នាពីការបរិច្ចាគទាន របស់ព្រះអង្គ" ។ ទើបព្រះដ៏មានបុណ្យទ្រង់ត្រាស់ថា 'ម្នាលភិក្ខុទាំងឡាយ, តថាគតបានបំពេញទានក្នុងកាលឥឡូវនេះ មិនជាទីអស្ចារ្យប៉ុន្មានទេ, កាលពីដើមដែលតថាគតបានបរិច្ចាគបុត្តភរិយារបស់ខ្លួន ឲ្យទៅជាខ្ញុំបម្រើអ្នកដទៃ នោះទើបមានសេចក្ដីអស្ចារ្យជាពន្លឹក" ទ្រង់មានព្រះពុទ្ធដីកាតែប៉ុណ្ណេះហើយក៏ទ្រង់គង់នៅស្ងៀម ។ គ្រានោះ ភិក្ខុទាំងឡាយអារាធនានិមន្តព្រះអង្គ

ឲ្យនាំអតីតនិទាននោះមកសំដែងប្រាប់ ។ ព្រះសាស្តាត្រាស់សំដែង អតីតនិទានតាមពាក្យអារាធនារបស់ភិក្ខុទាំងឡាយថា ៖

ម្នាលភិក្ខុទាំងឡាយ, ក្នុងកាលកន្លងទៅហើយ មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមព្រះបាទ វិបុល សោយរាជសម្បត្តិក្នុងនគរសុបរិត្ត, ព្រះអង្គមានអគ្គមហេសីទ្រង់ព្រះនាម សុន្ទរីទេវី, ព្រះរាជបុត្រីទ្រង់ព្រះនាមនាង សុចី ។ ព្រះរាជាអង្គនោះមិនមានព្រះទ័យលំអៀងដោយអគតិធម៌ណាមួយឡើយ, ទ្រង់សោយរាជ្យប្រកបដោយធម៌, ផុនចំណាយព្រះរាជទ្រព្យ ឲ្យជាងសង់សាលាសម្រាប់ឲ្យទាន ៥ ខ្នង ហើយទ្រង់ព្រះរាជទានព្រះរាជទ្រព្យដល់សមណយាចក អស់ចំនួន ៥ សែនកហាបណៈរាល់ៗថ្ងៃ ។

កាលនោះ អ្នកជម្ពូទ្វីបទាំងអស់ ឈប់ធ្វើវេជ្ជកម្ម ពាណិជ្ជកម្ម ចាំតែទទួលព្រះរាជទានអំពីព្រះរាជាប៉ុណ្ណោះ, ជនទាំងនោះបានជាអ្នកបរិបូណ៌ដោយទ្រព្យសម្បត្តិ ចាត់ចែងបង្កើតចម្រៀងរបាំកំប្រៀងកំសាន្តជាទីសប្បាយត្រេកពេក ។ ព្រះមហាសត្វទ្រង់ប្រព្រឹត្តសុចរិតធម៌ ទ្រង់ព្រះរាជទានព្រះរាជទ្រព្យ ដោយព្រះទ័យសោមនស្សយ៉ាងក្រៃលែងប៉ុណ្ណឹង ហើយក៏នៅតែមិនទាន់ស្កប់ស្កល់ក្នុងព្រះរាជហឫទ័យនៅឡើយ ។

ថ្ងៃមួយ ព្រះអង្គទ្រង់ប្រថាប់នៅលើប្រាសាទដ៏ប្រសើរ ទ្រង់បើកព្រះសីហបញ្ជរ ទតឥស្សរិយភាពរបស់ព្រះអង្គ ទើបទ្រង់មានព្រះ

តម្រិះថា "អញបានបំពេញតែពាហិរកទាន (ទានខាងក្រៅ) ប៉ុណ្ណោះ ឯអជ្ឈត្តិកទាន (ទានខាងក្នុង) អញមិនទាន់បានបំពេញសោះ", ទើបទ្រង់មានបំណងចង់ធ្វើអជ្ឈត្តិកទានទៀត; ទ្រង់រំពឹងថា 'បើអ្នកណាសូមក្បាលអញ, អញនឹងកាត់ក្បាលឲ្យអ្នកនោះ; បើអ្នកណាសូមភ្នែកអញ, អញនឹងឆ្កៀលភ្នែកឲ្យអ្នកនោះ; បើអ្នកណាសូមបេះដូងអញ, អញនឹងពុះទ្រូងអារសាច់សម្រក់ឈាម យកសាច់បេះដូងឲ្យអ្នកនោះ; បើអ្នកណាសូមសាច់អញ, អញនឹងពន្ធះសាច់ក្នុងសរីរៈទាំងមូលឲ្យអ្នកនោះ; ពុំនោះសោត បើមានអ្នកណាមួយមកនិយាយនឹងអញថា បពិត្រមហារាជ, សូមព្រះអង្គទៅធ្វើជាខ្ញុំបំរើខ្ញុំ ដូច្នេះក៏អញស៊ូតែទៅធ្វើជាខ្ញុំបំរើអ្នកនោះ" ។ កាលដែលព្រះរាជាកំពុងតែទ្រង់ព្រះចិន្តាការយ៉ាងនេះ ក៏ស្រាប់តែមហាប្រឹថពីដែលមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ កម្រើកញាប់ញ័រព្រួសព្រួរខ្ទរខ្ទើរឡើង ដូចជាជីវចុះប្រេងបញ្ចេញសំឡេងពេចខ្ទរខ្ទារគួរឲ្យខ្លាច, ភ្នំសិនេរុរាជក៏ទនលំទោនទោរទន់មក, ទាំងមហាសមុទ្រក៏កើតជារលកបោកបែកផ្កាត្រែង, មហាមេឃ ក៏បញ្ចេញសំឡេងគម្រាមដោយរន្ទះ ហើយបង្អុរមកនូវភ្លៀងរលឹមជាខ្លាំង, ទាំងផ្គរបន្ទោរពុំដូរកាលក៏ភ្លឺផ្លេកប្រាក, ពួកទេវតាក្នុងកាមាវចរសួគ៌ ក៏ឲ្យសព្ទសាធុការពរជ័យ, សេចក្ដីជ្រួលជ្រើមក៏កើតមានរហូតដល់ព្រហ្មលោក ។ សេចក្ដីអស្ចារ្យ ជាអនេកប្រការ ទឹងគណនាប្រាកប់ពុំបានឡើយ ។

ព្រោះហេតុនោះហើយ បានជាព្រះបរមសាស្តាចារ្យជាម្ចាស់ ទ្រង់ត្រាស់ថា:

តទា អារុយ្ហ បាសាទេ ឱលោកេត្វា មហាសិរឹ
សុទ្ធចិត្តំ ឧប្បាទេត្វា ទានំ ទាតុំ វិចិន្តយិ
សីសំ សបេបំ បក្កញ្ច ហទយញ្ចាបិ មំសកំ
ទទេយ្យំ កាយំ សាវេត្វា យទិ កោចិ យាចេយ្យ មំ
សភាវំ ចិន្តយន្តស្ស អកម្បិតមសណ្ឋិតំ
អកម្បិ តត្ថ បឋវី សិនេរុវនវដំសកាតិ

ក្នុងកាលដែលតថាគតឡើងទៅលើប្រាសាទ រមិលមើលទ្រព្យសម្បត្តិធំ ញុំាងចិត្តដ៏ស្អាតឲ្យកើតឡើង ដើម្បីនឹងឲ្យទានហើយ មានសេចក្តីត្រិះរិះថា "បើអ្នកណាប្រាថ្នាចង់បានក្បាលភ្នែក បេះដូង ឬសាច់របស់អញ អញអាចកាត់ឆ្កៀលពន្លះឲ្យទៅអ្នកនោះ ដោយឥតញញើតឡើយ"; តថាគតកំពុងតែត្រិះរិះដូច្នោះ ស្រាប់តែមហាប្រឹថពីកំរើកញាប់ញ័រស្ទើរតែទប់ទល់ទ្រទ្រង់នៅពុំបាន, ទាំងភ្នំសិនេរុក៏គោនលំទោន ទោរទន់ល្ងាសល្ងន់មករកតថាគត ។

កាលនោះទីសយនាក្រឡាបន្ទំនៃសក្កទេវរាជ ក៏ក្តៅក្រហាយដោយតេជានុភាពនៃទានបារមី ។ សម្តេចសហស្សនេ័យន៍ទ្រង់ប្រមើលមើលឃើញហេតុនោះហើយក៏លាន់ព្រះឱស្ឋថា ឱហ្ន៎! ព្រះបាទវិបុលរាជជាពុទ្ធង្កុរបណ្ឌិតពុទ្ធវង្ស ទ្រង់ឋិតនៅក្នុងមនុស្សលោកឯណោះ មានព្រះរាជសទ្ធាបានចំណាយព្រះរាជទ្រព្យ ឲ្យទៅជាទានដល់សមណយាចកអ្នកកំសត់ទុគ៌ត ដោយឥតការឡោះអាល័យសោះ ដល់ម្ល៉ោះទ្រង់ក៏មិនបានស្កប់ព្រះរាជហឫទ័យក្នុងពាហិរកទាន ឥឡូវទ្រង់គិតថា នឹងបំពេញអជ្ឈត្តិកទានទៀត" ។ សក្កទេវរាជទ្រង់អាវជ្ជនាការពិចារណាឃើញហេតុដូច្នេះហើយ ក៏ក្លែងភេទជាព្រាហ្មណ៍ចេញមកអង្គុយក្នុងសាលាទាន ។

គ្រានោះ ព្រះរាជាទ្រង់ស្រង់ព្រះឧទកតាំងពីព្រលឹម ហើយទ្រង់សោយព្រះស្ងោយមានឱជារសផ្សេងៗ ស្រេចស្តេចទ្រង់ប្រដាប់គ្រឿងអលង្ការ ក្សត្រាទ្រង់ឡើងគង់លើព្រះទីនាំងគជេន្ទ្រ មានពួកអាមាត្យហែហមជាបរិវារ ទ្រង់យាត្រាឆ្ពោះទៅកាន់ទានសាលា, លុះដល់កាលណាក៏ទ្រង់ចុះចាកព្រះរាជទីនាំង ចូលទៅក្នុងសាលា ទ្រង់បែងចែកព្រះរាជទ្រព្យព្រះរាជទានក្នុងពេលនោះតាមធម្មតា ។ គ្រានោះ ឥន្ទព្រាហ្មណ៍លើកកំបង់អញ្ជលីដាក់លើសិរសាក្រាបថ្វាយបង្គំទូលថា "បពិត្រព្រះសម្មតិទេពវង្ស ទ្រង់នូវព្រះរាជសម្ភារ, សូមព្រះអង្គមានជ័យជំនះឈ្នះអស់សត្រូវសព្វគ្រប់ប្រការ" ជាដូច្នេះ ហើយក៏ឋិតនៅក្នុងទីដ៏សមគួរ ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះសវនាការពាក្យនោះហើយ ទ្រង់ត្រាស់ថា "ព្រាហ្មណ៍នេះចង់បានអ្វីអេះ? បើដូច្នេះ អញនឹងសួរមើល" កាលមានព្រះបន្ទូលសួរនូវហេតុនោះទើបត្រាស់នូវបឋមគាថាថា:

ហរិតសរីរោ តវញ្ច ទស្សនីយោ សុរូបិយោ
បគ្គយ្ហ អញ្ជលិញ្ចេវ កឹ មំ យាចសិ ព្រាហ្មណាតិ

ម្នាលព្រាហ្មណ៍, អ្នកឯងមានសរីរៈហាក់ដូចជាលាបស្រឡាបដោយខ្មីមចន្ទន៍ក្រហម គួរឲ្យអ្នកផងក្រឡេកមើល, រូបអ្នកសោតក៏ស្រស់បំព្រង គួរឲ្យអ្នកផងគយគន់, អ្នកមកអង្គុយប្រណម្យអញ្ជលីនៅទីនេះ តើអ្នកចង់បានអ្វី? ។

ព្រាហ្មណ៍បានស្ដាប់ហើយ ក៏មានចិត្តរីករាយត្រេកអរក្រាបបង្គំទូលសុំព្រះរាជទេពី ទើបក្រាបទូលនូវព្រះគាថាទីពីរថា:

យថា ភារិយោ ប្លវោ សព្វកាលំ ន ខីយតិ
ឯវិទ្ធិ យាចិតាគញ្ញ ទេវី មេ ទេហិ យាចិតោតិ

បពិត្រព្រះនរបតី, ទឹកក្នុងបឹងស្ទឹងព្រែក តែងហូរទៅកាន់សមុទ្រសព្វកាល មិនចេះអស់យ៉ាងណា ព្រះរាជទ្រព្យរបស់ព្រះករុណា ក៏តែងតែផ្ទះថ្វាក្នុងការព្រះរាជទានពុំមានអស់យ៉ាងនោះដែរ; ទូលព្រះបង្គំជាខ្ញុំមកសូមព្រះនាងទេវី សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទានកុំខាន ។

ព្រះរាជាទ្រង់បានព្រះសវនាការពាក្យព្រាហ្មណ៍ក្រាបបង្គំទូលសូមព្រះនាងទេវីដូច្នោះហើយ, ទ្រង់ក៏មានព្រះបរិតសោមនស្សអស់ពីព្រះរាជហឫទ័យ ហាក់ដូចជាបុរសកំសត់បានមាស ១ ពាន់ដំឡឹងអំពីសំណាក់ព្រះមហាក្សត្រ ទើបទ្រង់មានព្រះរាជនុស្ការត្រាស់នូវគាថាគំរប់ ៣ ថា:

ទទាមិ ន វិកម្បាមិ  យំ មំ យាចសិ ព្រាហ្មណ
សន្តំ ន បតិគុយ្ហាមិ  ទានេ រមតិ មនោតិ

ម្នាលព្រាហ្មណ៍, អ្នកសូមរបស់អ្វី យើងឲ្យរបស់នោះឥតទើសទាល់ទេ យើងមិនលាក់ទុករបស់ដែលមានទេ, ចិត្តយើងត្រេកអរចំពោះការឲ្យទានតែម្យ៉ាង ។

ទើបទ្រង់ត្រាស់ហៅព្រះនាងទេវីមកប្រាប់ថា: «ម្នាលប្អូនស្រីជាទីស្រឡាញ់ពេញចិត្ត, ដ្បិតព្រាហ្មណ៍នេះមកសូមនាង យើងប្រាថ្នាសព្វញ្ញុតញ្ញាណ ចូរនាងបំពេញទានបារមីដល់យើងឲ្យបានសម្រេចដូចសេចក្ដីប្រាថ្នាចុះ ។ ឯអគ្គមហេសីជាស្ដ្រីគ្រប់លក្ខណ៍ លុះបានស្ដាប់ដាក់ក៏មានព្រះរាជហឫទ័យត្រេកអរសោមនស្សអស់ពីព្រះចិន្ដា ហើយមានព្រះរាជសវនីយទទួលព្រះរាជនុស្ការថា:

ទាសី តុយ្ហំ អហំ ទេវ  សាមិកោ មម តស្សេវ
យស្សិច្ឆេ តស្ស មំ ទជ្ជា  វិក្កិណេយ្យ ហនេយ្យ វាតិ

បពិត្រព្រះរាជសម្ភារ, សូមទ្រង់ព្រះករុណាមេត្តាប្រោស,

ខ្ញុំម្ចាស់ជាទាសីរបស់ព្រះអគ្គស្រាប់ ព្រះអង្គជាម្ចាស់លើខ្ញុំព្រះអង្គ, បើព្រះអង្គត្រូវការព្រះរាជទានដល់នរណា, សូមទ្រង់ព្រះរាជទានតាមសព្វព្រះរាជហឫទ័យ; ទុកណាជាព្រះអង្គត្រូវការលក់ដូរយ៉ាងណាក្ដី សម្លាប់បង់ក្ដី ក៏ស្រេចនឹងព្រះរាជហឫទ័យព្រះអង្គស្រាប់ ។

ព្រះរាជាទ្រង់ព្រះសវនាការព្រះរាជសវនីយ នៃព្រះអគ្គមហេសីដែលទទួលព្រមដូច្នោះហើយ ក៏ទាញយកក្អមមាសហើយចាប់ព្រះហស្ដព្រះអគ្គមហេសី បួងសួងយកផែនដីជាបន្ទាល់, ទ្រង់ផ្ដិតស្មោទកហើយត្រាស់យ៉ាងនេះថា "ម្នាលព្រាហ្មណ៍, កិរិយារបស់យើងជាទីស្រឡាញ់ពេញចិត្តក្រៃពេក, ប៉ុន្តែយើងចង់បានសព្វញ្ញុតញ្ញាណលើសលុបជាងនេះ មិនអាចកប់ថា ១ រយគុណ ១ ពាន់គុណ ១ សែនគុណបានឡើយ, បានជាយើងស៊ូលះបង់នាងទេវីជាទីស្រឡាញ់ពេញចិត្ត ឲ្យដល់អ្នកឯងយើងមិនប្រាថ្នាសម្បត្តិមនុស្ស សម្បត្តិសួគ៌ សម្បត្តិព្រះឥន្ទ្រ សម្បត្តិព្រហ្ម សម្បត្តិសាវ័ក សម្បត្តិបច្ចេកពុទ្ធឡើយ ប្រាថ្នាចំពោះសព្វញ្ញុតញ្ញាណតែម្យ៉ាង" លុះទ្រង់ត្រាស់ដូច្នេះហើយ ទ្រង់ព្រះរាជទានព្រះអគ្គមហេសីដល់ព្រាហ្មណ៍ក្នុងកាលនោះឯង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ សម្ដេចព្រះបរមសាស្ដាចារ្យកាលទ្រង់ប្រកាសសេចក្ដីនោះទ្រង់ត្រាស់ថា៖

ទេវឹ ហត្ថេ គហេត្វាន ឧទកមណ្ឌលុំ គណ្ហិ
បសន្នមនសង្កប្បោ តស្ស ទេវឹ អទាសិ សោ
ទេវិយា ទទមានាយ បិយបុត្តេន បមោទិតោ
តស្មា បឋវី កម្បតិ សិនេរុវនវដំសកាតិ

ព្រះរាជាអង្គនោះបានចាប់ព្រះហស្តព្រះនាងទេវី ហើយកាន់យកក្អមទឹកមានព្រះទ័យជ្រះថ្លា បានប្រទានព្រះនាងទេវីដល់ព្រាហ្មណ៍នោះ កាលបើទ្រង់ព្រះរាជទានព្រះនាងទេវីរួចហើយក៏មានព្រះទ័យត្រេកអរជ្រះថ្លា យ៉ាងក្រៃលែង, ព្រោះហេតុនោះ បានជាមហាប្រឹថពីញាប់ញ័រ ទាំងភ្នំសិនេរុក៏អោនលំទោនទៅទន់ ៗ

ឯព្រាហ្មណ៍នោះបាននាងទេវីហើយ ក៏នាំយកបាត់ពីទីនោះទៅភ្លាម ៗ ក្បែរណានោះ ឥន្ទព្រាហ្មណ៍ជាតួអង្គសក្កទេវរាជ និម្មិតជាព្រាហ្មណ៍ថ្វែក មកថ្វាយសព្ទសាធុការ ហើយពោលថា

យថា វារិវហោ បូរោ សព្វកាលំ ន ខីយតិ
ឯវន្តំ យាចិតាគញ្ឆិំ បត្តិំ មេ ទេហិ យាចិតោតិ

បតិព្រតព្រះរាជសម្ភារ, ដម្កតាទឹកស្ទឹងបឹងព្រែកតែងហូរទៅកាន់សមុទ្រសព្វ ៗ កាល មិនចេះអស់យ៉ាងណា ព្រះទ័យ

ព្រះករុណា គឺតែងព្រះថ្វាកនូវការព្រះរាជទានមិនចេះអស់យ៉ាងនោះដែរ; បពិត្រព្រះនរបតី, ទូលព្រះបង្គំជាខ្ញុំមកសូមព្រះរាជបុត្រី សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទាន ។ ព្រះរាជាទ្រង់ព្រះសវនាការពាក្យនោះហើយ ក៏មានព្រះរាជហឫទ័យសោមនស្សជ្រះថ្លា ទើបមានព្រះរាជឱង្ការថា:

ទទាមិ ន វិកម្បាមិ យំ មំ យាចសិ ព្រាហ្មណ
សន្តំ នប្បតិគុយ្ហាមិ ទានេ មេ រមតី មនោតិ

ម្នាលព្រាហ្មណ៍, យើងជាឥស្សរៈ យើងឥតធុញទ្រាន់នឹងការឲ្យទេ អ្នកឯងចាំតែនាំយករបស់ដែលយើងឲ្យចុះ, យើងមិនលាក់លៀមរបស់ដែលមានទេ, ចិត្តយើងត្រេកអរតែក្នុងការបរិច្ចាគទានតែម្យ៉ាង ។

លុះព្រះអង្គទ្រង់ត្រាស់ដូច្នោះហើយក៏បញ្ជូនព្រះរាជបុត្រីឲ្យទៅស្រង់ស្អិតស្អាងព្រះកាយដោយគ្រឿងអលង្ការគ្រប់យ៉ាង ហើយហៅមកឲ្យគង់លើអាសនៈ. ទ្រង់ជប់ព្រះសិរលួងលោមផ្ដាំសព្វគ្រប់សេចក្ដីព្រះចក្រីកាលនឹងទ្រង់ប្រកាសដល់អស់ទេវតាទាំងពួង យកជាបន្ទាល់សាក្សី ទើបទ្រង់ត្រាស់នូវព្រះគាថាថា:

ហាហា ភោន្តោ ទេវសង្ឃា សព្វេ ទេវា សមាគតា
ទានំ មេ អនុមោទន្តុ បុញ្ញំ គណ្ហន្តុ ឦទិសំ

តស្ស បុត្តិញ្ច ទស្សាមិ   បិយំ បិត្តេន ទេមិហំ

បុត្តិមហំ សុភជាតិ   ពោធិយា យេវ ការណាតិ

បពិត្រទេវតាទាំងឡាយអើយ ! សូមពពួកទេវតាអញ្ជើញមកជួបជុំជាបន្ទាល់សាក្សីពេជ្ញាណ សូមជួយអនុមោទនាទាននៃខ្ញុំ ហើយសូមទទួលយកចំណែកបុណ្យនេះ ដ្បិតខ្ញុំបានឲ្យបុត្រីជាទីស្រឡាញ់ពេញចិត្តប្រកបដោយរូបឆោមប្រពៃ ដើម្បីនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដក្នុងអនាគត ។ លុះទ្រង់ត្រាស់ដូច្នោះហើយ ក៏ព្រះរាជទានព្រះរាជបុត្រីដល់ព្រាហ្មណ៍ក្នុងកាលនោះឯង ។

គ្រានោះកើតមានសេចក្ដីអស្ចារ្យជាអនេកប្រការ ដោយតេជ:នៃការបរិច្ចាគទាន ដែលពុំមាននរណាធ្វើដូចបាន ។ ព្រោះហេតុនោះបានជាអង្គសម្ដេចព្រះទ្រង់ញាណទ្រង់មានព្រះពុទ្ធដីកាថា:

តទាសិ យំ ភឹសនកំ   តទាសិ លោមហំសនំ

រាជបុត្តិម្ហិ បទិន្នម្ហិ   មេទនី សមកម្បថ ។

អច្ឆរិយំ ប អាសិ សោ   ឃោសោ ប វិបុលោ មហា

បុត្តិភរិយេ បទិន្នម្ហិ   សកលសគ្គំ កម្បថាតិ

ក្នុងកាលដែលតថាគតបានឲ្យបុត្រីទៅជាទាន តថាគតមានសេចក្ដីព្រឺព្រួចញ័រសព្វសពាង្គកាយ ទាំងផែនប្រឹថពីជាទី

ទ្រទ្រង់សត្វទាំងឡាយ ក៏គក្រើករំពើកញាប់ញ័រ ទាំងឋាន
សួគ៌ជាទីនៅអាស្រ័យ នៃពួកទេពនិករ ក៏ញាប់ញ័រអស្ចារ្យ
ជាពន្លឹក ។

គ្រាដែលព្រះមហាសត្វទ្រង់ព្រះរាជទានរូបហើយ ទ្រង់កំពុងមាន
ព្រះរាជហឫទ័យរីករាយសោមនស្សស្រស់ស្រាយ ស្រាប់តែសក្កទេវរាជ
ដែលនាំយកព្រះរាជបុត្រីពីទីនោះទៅ ក៏ក្លែងភេទជាព្រាហ្មណ៍ចាស់ប្លែក
ដៃកាន់ឈើច្រត់ មានសក់ស្កូវ មានពុកមាត់ពុកចង្កាវែង ៗ មកអង្គុយ
ទៀបទ្វារព្រះរាជដំណាក់ ។ ព្រះរាជាទ្រង់ទស្សនាការទតឃើញ
ព្រាហ្មណ៍នោះហើយ ក៏ត្រាស់សួរថា:

អបិ ត្វំ កេន វណ្ណេន កេន វា បន ហេតុនា
អនុប្បត្តោសិ ឥតរំ តំ មេ អក្ខាហិ បុច្ឆិតោតិ

នែអ្នកដែលមានរូបអន្ធការ, អ្នកមកពីណា ? មានការអ្វី?
ចូរអ្នកប្រាប់យើងឲ្យដឹងសេចក្តី កុំបីកោតញញើត ។
គ្រានោះ សក្កទេវរាជបានស្តាប់ព្រះរាជឱង្ការហើយ ក៏ក្រាបបង្គំ
ទូលថា:

ជិណ្ណោបាមស្មិ អាគតោ ទីឃមទ្ធានមាគតោ
សុត្វាន សុបរិតញ្ច រាជ អាគតោស្មិ តវ
សន្តិកេ អនុជានាហិ ឥតរំ ទេហិ ត្វំ មមាតិ

បពិត្រព្រះរាជសម្ភារជាបរមក្សត្រដ៏ប្រសើរ ទូលព្រះបង្គំជាខ្ញុំជាមនុស្សចាស់ជរាមកពីស្រុកឆ្ងាយដាច់សង្វែង ឮដំណឹងថាព្រះអង្គទ្រង់ប្រកបដោយសេចក្ដីសុចរិត ព្រមទាំងមានព្រះរាជសទ្ធា បានជាទូលព្រះបង្គំជាខ្ញុំមកដើម្បីសូមព្រះនគរ, សូមទ្រង់ព្រះរាជានុញ្ញាតព្រះរាជទាននគរដល់ទូលព្រះបង្គំជាខ្ញុំ ។

ព្រះមហាសត្វទ្រង់ព្រះសវនាការហើយ ក៏មានព្រះបិតិសោមនស្សអស់ពីព្រះទ័យ ទើបទ្រង់លះបង់ព្រះសិរីរាជសម្បត្តិ ព្រះរាជទានដល់ព្រាហ្មណ៍, ទ្រង់មានព្រះរាជឱង្ការថា:

គណ្ហាហិ តវំ ឥច្ចម្ហិ ឥស្សរោ នយ ព្រាហ្មណ
មនោរថំ បូរេស្សាមិ ទានេ មេ រមតី មនោតិ

ម្នាលព្រាហ្មណ៍, ចូរអ្នកជាធំលើនគរ តាមសេចក្ដីប្រាថ្នារបស់អ្នកចុះ, យើងនឹងបំពេញសេចក្ដីប្រាថ្នារបស់អ្នកឲ្យបានពេញលេញដូចបំណង ព្រោះចិត្តយើងតែងត្រេកអរតែក្នុងការបរិច្ចាគទាន ។

ទើបព្រះរាជាចាប់យកកន្ទីរមាស មកជ្រួចស្នាទឹក ហើយទ្រង់ព្រះរាជទាននគរនោះ ដោយព្រះរាជឱង្ការរួសរាយថា:

ឥទំ ហិ នគរំ មយ្ហំ សព្វលោកសមិទ្ធិនំ
ទត្វាន នគរំ ឥទំ ខេឡបិណ្ឌំ វ ឆឌ្ឌិតំ

សំសារតរណត្ថាយ កាមរាគមហណ្ណវេ
សព្វេ សត្តា បរិត្តារំ បាបុណិស្សាមិ និព្វុតិន្តិ

នគររបស់យើងនេះ ស្តុកស្តម្ភជាងស្រុកដែលមាននៅក្នុងលោកទាំងអស់ យើងបានឲ្យនគរនោះ ផុតស្រឡះពីដួងចិត្តឥតមានសេចក្តីស្តាយស្រណោះ ដូចជាបុគ្គលស្តោះបោលទូវដុំនៃទឹកមាត់ដូច្នោះ; សព្វសត្វទាំងឡាយដែលវិលកើតស្លាប់នៅក្នុងមហាសមុទ្រគឺកាមរាគនោះច្រើនណាស់; យើងប្រាកដជានឹងបានជួយសត្វទាំងនោះ ឲ្យឆ្លងចាកសង្សារវដ្តទៅកាន់ព្រះនិព្វានបានពុំខាន ។

សម្តេចព្រះសក្កទេវិន្ទ្រពិនិ្ទអមរ បានឃើញទឹកព្រះទ័យគួរជាទីអស្ចារ្យក៏លាន់ព្រះឱស្ឋថា "ឱហ្ន៎! ព្រះរាជានេះប្រាកដជាពុទ្ធង្កុរបណ្ឌូលពុទ្ធវង្សជាអគ្គសព្វញ្ញុពុទ្ធ ជាទីពឹងពាក់សំណាក់អាស្រ័យនៃមនុស្សនឹងទេវតាទាំងឡាយទៅឯអនាគតពុំខានឡើយ", ហើយក៏បង្គំទូលព្រះរាជាថា "បពិត្រមហារាជ, ខ្ញុំជាព្រះឥន្ទ្រទេតេ មិនមែនព្រាហ្មណ៍ទេ, ខ្ញុំបានឃើញព្រះអង្គប្រព្រឹត្តសុចរិតធម៌ បានជាមកជួយបំពេញសព្វញ្ញុតញ្ញាណ; បពិត្រមហារាជ, សូមព្រះអង្គទទួលយកបុត្រីនឹងអគ្គមហេសីនឹងនគរ ព្រះអង្គវិញចុះ" ។ សក្កទេវរាជ ក៏ប្រគល់ព្រះរាជបុត្រីនឹងអគ្គមហេសីថ្វាយ

ព្រះបាទវិបុលកជហើយនូនព្រះសិរគំនាប់ដោយសមគួរ ទើបក្លែងភេទជា ព្រះឥន្ទមានព្រះកាយដ៏រុងរឿងល្អក្រៃពេក ហោះផ្លោះផ្លុកឡើងទៅកាន់អាកាស ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ដំណើរសេចក្តីតាមរឿងនេះ ដែលពុំទាន់ប្រាកដ លុះសម្តេចព្រះសុគតបរមសាស្តា បានត្រាស់ឡើងកាលណា ទើបទ្រង់ប្រកាសសេចក្តីនោះឲ្យប្រាកដឡើងថា:

តស្ស សង្កប្បមញ្ញាយ មឃវា ទេវកុញ្ជរោ
អាកាសគគណេ ឋត្វា ឥទំ វចនមព្រវិ
និន្ទាទិតា តេ បបរី សន្តោ តេ តិទិវង្គតោ
សមន្តា វិជ្ជុតា អាគូ គីរឹ វ បតិស្សុតា
តស្ស តេ អនុមោទន្តិ ឧភោ នារទបព្វតា
ឥន្ទោ ព្រហ្មា បជាបតិ សោមោ យមោ វេស្សវណោ
សព្វេ ទេវា អនុមោទន្តិ ទុក្ករំ ហិ ករោតិ សោ
ទុទ្ទទំ ទទមានានំ ទុក្ករំ កម្មកុព្វតំ
អសន្តោ នានុកុព្វន្តិ សតំ ធម្មោ ទុរន្នយោ
តស្មា សតញ្ច អសតំ នានា ហោតិ ឥតោ គតិ
អសន្តោ និរយំ នេតិ សន្តោ សគ្គបរាយនោតិ

មឃវៈជាទេវកញ្ញា បានជ្រាបនូវការៈចិត្តព្រះមហាសត្វនោះ ហើយក៏ហោះផ្លោះឡើងទៅកាន់អាកាស ប្រកាសសរសើរទានបារមីថា ផែនដីរបស់ព្រះអង្គញាប់ញ័រហើយ កិត្តិស័ព្ទរបស់ព្រះអង្គ ផ្សាយទៅហើយរហូតដល់ពិភពត្រៃត្រឹង្ស ទាំងផ្ទុកបន្ទោរក៏ជាលង្វៀលផ្ទាត់ប្រពាត់ជុំវិញ សព្វទិសនានា សេចក្ដីអស្ចារ្យមានប្រាកដ រហូតដល់សព្វគិរីបរពត សមុទ្រសាគរហាក់ដូចជាមានអំណរជួយត្រេកអរ ចំពោះទានបារមីនៃព្រះអង្គ ទាំងពួកអមរវង្សអង្គឥន្ទ្រព្រហ្មបជាបតី ទាំងព្រះអាទិត្យព្រះចន្ទ្រ ព្រះយមរាជព្រះវេស្សវ័ណក៏សឹងមានសេចក្ដីត្រេកអរគ្រប់ៗគ្នា ទទួលអនុមោទនាសរសើរព្រះអង្គថា ឱ! ព្រះបាទវិបុលរាជអើយ! ព្រះអង្គទ្រង់បរិច្ចាគទានឥតមាននរណាធ្វើដូចព្រះអង្គបានឡើយ, បុគ្គលជាសប្បុរសតែងឲ្យរបស់ដែលគេឲ្យបានដោយក្រម តែងធ្វើនូវអំពើដែលអ្នកទាំងពួងធ្វើបានដោយក្រម, ឯអសប្បុរសធ្វើតាមយ៉ាងនេះផងពុំបានទេ, ធម៌របស់ពួកសប្បុរសទាំងឡាយ គឺពួកអសប្បុរសក្រមទឹងប្រព្រឹត្តតាមកើតណាស់ ព្រោះហេតុនោះ បានជាសប្បុរសនឹងអសប្បុរសតែងមានគតិ

ដំណើរអន្ទោលទៅកាន់គតិផ្សេងគ្នា គឺអសប្បុរសតែងទៅកាន់ទុគ្គតិភព សប្បុរសរមែងទៅកាន់ស្ថានសួគ៌ ។

សក្កទេវរាជនោះលុះពោលសរសើរព្រះបាទវិបុលរាជរួចហើយ ក៏ហោះត្រឡប់ទៅកាន់ឋានអាត្មាវិញហោង ។

ឥមត្ថំ បកាសេន្តោ សត្ថា អាហ ព្រះសាស្តាចារ្យយាវង្ស កាលទ្រង់ប្រកាសសេចក្តីនោះទ្រង់ត្រាស់ថា:

ឥទំ វត្វា ន មឃវា ទេវរាជា សុជម្បតិ
ពោធិសត្តំ ឫតិ កត្វា សគ្គកាយំ អបក្កមាតិ

ទេវរាជឈ្មោះមឃវា ជាស្វាមីនៃនាងសុជាតា ពោលសរសើរព្រះពោធិសត្វដូច្នេះហើយ ក៏គៀសខ្លួនចៀសចេញទៅកាន់ទេវលោកទៅ ។

ព្រះបាទវិបុលរាជនៅក្រុងសុចិវត្តិស្រីមហានគរ ទ្រង់ប្រកបដោយទសពិធរាជធម៌ឥតមានល្អក់កករ ក្នុងព្រះរាជហឫទ័យឡើយ ហើយទ្រង់សន្សំបុណ្យទាំងឡាយមានទានជាដើម រៀងរាបដរាបដល់អស់ព្រះជន្មាយុ ស្តេចបានទៅសោយសេចក្តីសុខក្នុងទេវលោក ។

សម្តេចព្រះបរមសាស្តាចារ្យ ទ្រង់នាំធម៌ទេសនាមកសំដែងប្រាប់ភិក្ខុទាំងឡាយថា "ម្នាលភិក្ខុទាំងឡាយ តថាគតបានឲ្យទានដ៏ធំនេះមិនមែនតែក្នុងកាលឥឡូវនេះទេ, កាលពីមុនដែលតថាគតកើតជាស្តេច

វិបុលរាជ កំតថាគតបានឲ្យទានមានសេចក្ដីអស្ចារ្យជាអនេកប្រការយ៉ាងនេះដែរ ។ លុះត្រាស់ដូច្នោះហើយព្រះអង្គប្រកាសនូវសច្ចធម៌ទាំងឡាយ ទើបទ្រង់ប្រជុំជាតកកន្លងទីបំផុតនៃសច្ចកថាថា "ស្ដេចទេវតាបានចេរវិលវិលមកកើតជាភិក្ខុឈ្មោះអានន្ទ, នាងសុន្ទរីទេវីជាអគ្គមហេសីព្រះបាទវិបុលរាជ បានចេរវិលមកកើតជានាងយសោធរាពិម្ពា ជាមាតារាហុល, នាងសុចីជារាជបុត្រីនៃព្រះរាជានោះ បានមកកើតជានាងកណ្ឋកគោត្រី, ពួកជនអ្នកប្រទេសសុចិរត្តិកន្លងកាលណោះ គឺជាពុទ្ធបរិស័ទរបស់តថាគតកន្លងកាលឥឡូវនេះ, ព្រះបាទវិបុលរាជ គឺជាអង្គតថាគតដែលជាទីពឹងរបស់សត្វលោកហ្នឹងឯង ។

សូមអ្នកទាំងឡាយជាពុទ្ធបរិស័ទ ចងចាំចំណាំជាតកនេះ ដោយប្រការយ៉ាងនេះឯង ។

ចប់ វិបុលរាជជាតកទី ៦ តែប៉ុណ្ណេះ

ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៉ិង-ប៉ម
អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង
ឃុនបណ្ណារក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ

(តចប់)

---

៥— ចេះផ្ចាញ់ខ្លួនឯង — ការផ្ចាញ់ខ្លួនឯង គឺផ្ចាញ់ចិត្តខ្លួនឯង ដោយការតស៊ូប្រាំងការពារខាងខា នូវអំណាចខាងទាបគឺសេចក្ដីអាក្រក់ ដោយអំណាចខាងខ្ពស់គឺសេចក្ដីល្អ ។ យើងដែលនឹងផ្ចាញ់ខ្លួនឯងនោះ ត្រូវតែជាអ្នកតស៊ូដ៏រឹងប៉ឹង នឹងធឹង អង់អាច មាំមួននឹងខែងរ៉ែង រឹងជំហរ ដូចជាកំពែងថ្ម តាំងវិន័យបង្គាប់ចិត្តខ្លួនឯងឲ្យនៅក្នុងអំណាចខាងខ្ពស់ ដូចជាសតិសម្បជញ្ញៈ, ប្រឹងប្រែង, ព្យាយាម, អង់អាច, ក្លាហាន, អត់ធ្មត់, មេត្តា, ករុណា, មុទិតា, ហិរិ, ឧត្តប្បៈ, ស្មោះត្រង់, សុចរិត, កតញ្ញូ, សម្មាគារវៈ, យុត្តិធម៌ នឹងសុភាពរៀបរយជាដើម ។ សូម្បីបេះដូង (ចិត្ត) យើងតូចតាចចង្អៀតក៏ដោយ ក៏គួរដាក់បញ្ចុះ ខ ទាំងនេះទុក ព្រោះសេចក្ដីល្អទុកដូចជាសាច់មាសបរិសុទ្ធពិតៗ ។ ខ្លួនយើងនឹងមានសណ្ឋានតូចឬធំនោះ លើកទុកចុះ តែគួរធ្វើឲ្យកម្លាំងចិត្តធំជាងសណ្ឋានទ្រង់ទ្រាយរូបកាយ ឬយ៉ាងហោចណាស់ ក៏កុំឲ្យតូចជាងកាងរៅ

ដែរ សូម្បីអំណាចខាងទាបដូចយ៉ាង ល្ងង់ខ្លៅមិនស្គាល់ខុសត្រូវ, ខ្ជិលច្រអូស, មាក់ងាយ, មឹតពត់, រញ្ជួញ, ប្រឆេងប្រឆាំង, ឃោរឃៅ, ឫស្យា, ឈ្នានីស, វៀចវេរ លុបគុណ, ក្អេងក្អាង, អំនួត នឹងកិរិយា ពាលាអាក្រក់ក្រោតក្រោធជាដើម ជន្លគ្នាយ៉ាងខ្លាំងខ្លាបបួល មកញាំញីក៏ដោយ ក៏យើងត្រូវខំតស៊ូឲ្យវាវតថយវិនាសទៅវិញតាមគ្នា បើយើងធ្វើបានយ៉ាងនេះ រង្វាន់គឺការឈ្នះខ្លួនឯង ក៏បានជារបស់យើងដាច់ខាត ។

ការផ្ចាញ់មនុស្សទាំងពួង ដោយហេតុដទៃ ដូចយ៉ាងគេក្រោធខឹង យើងក៏ក្រោធខឹងតប យ៉ាងហោចណាស់ ក៏ប្រើវាចាពោលស៊ិកសៀតចាក់ដោតឲ្យគេវិញ ឬប្រើកាយឲ្យវាយទះតប់គ្នា បើឈ្លោះគ្នាយ៉ាងខ្លាំងក៏ប្រើមុខសស្ត្រាវុធចាក់កាប់បាញ់សម្លាប់គ្នា តាំងអំពីតគួរហូតដល់កជាពួកជាកងចូលប្រឡូកគ្នានោះ សូម្បីយើងឈ្នះគេបានដោយសេចក្តីក្លាហានអង់អាច មិនមាននរណាហ៊ានតបតមកវិញក៏ដោយ ក៏ការឈ្នះដែលបង្កសេចក្តីក្រវល់ក្រវាយ នឹងការញាំញីប្រទូសរ៉ាយដែលជាទីតាំងនៃសេចក្តីក្តៅក្រហាយ ឲ្យកើតឡើងដល់ខ្លួនយើងដែរ ចូលក្នុងទំនងថា "បាចទឹកដាក់គ្នា" ឬ "លាងជម្រះរបស់ស្មោកគ្រោកដោយទឹកក្រខ្វក់, លត់ភ្លើងដោយបង្គរទុស" ហេតុនេះ ទើបយើងមិនគួររីករាយចំពោះការបរាជ័យរបស់មនុស្សដទៃ នឹងមិនគួររីករាយចំពោះជ័យជំនះរបស់ខ្លួនដោយ

ហេតុយ៉ាងនេះទេ ។ ព្រោះការឈ្នះបែបនេះ ជាជំនះមិនពិត អាច ត្រឡប់ចាញ់វិញបាន មិនមែនជាវិធីរម្ងាប់ពៀរទេ ត្រឡប់ជាវិធីជាប់ ជំពាក់ដោយពៀរភ័យទៅវិញ ។ គង់បច្ចុប្បន្នយើងឈ្នះគេយ៉ាងណា គង់ អនាគតគេនឹងត្រឡប់ឈ្នះយើងវិញយ៉ាងនោះ ។ យើងឈ្នះគេប៉ុណ្ណា នឹងត្រូវត្រឡប់ចាញ់គេវិញប៉ុណ្ណោះ ដូមនឹងការឈ្នះខ្លួនឯងពុំបាន ឡើយ ។ ព្រោះការឈ្នះខ្លួនឯងនេះជាជំនះដ៏ប្រសើរ, ជាជំនះដ៏លើស លុប ជាជំនះដាច់ស្រេចមិនដែលត្រឡប់ចាញ់វិញ, ជាវិធីមិនជាប់ជំពាក់ ដោយវេរភ័យ, ជាទីតាំងនៃសេចក្តីក្សេមក្សាន្តផុតពៀរភ័យគ្រប់ផ្នែក; អ្នកឈ្នះខ្លួនឯងឈ្មោះថាជាចមពលនៃចមពល ខ្ពស់ជាងចមពលដែល ឈ្នះមនុស្សរាប់លានជាច្រើនលានដងក្នុងសង្គ្រាមទៅទៀត ។

គង់កាសិតជយសូត្រ ពោលដល់ការសង្គ្រាមរវាងទេវតាដែលមាន ព្រះឥន្ទ្រជាមេទ័ពតទល់នឹងពួកអសុរ ដែលមានព្រះបាទវេបចិត្តាសូរជា នាយកដឹកនាំ ដែលមានមកជាច្រើនលើកច្រើនគ្រា; គ្រាមួយ ព្រះបាទ វេបចិត្តាសូរដឹកនាំព្រះឥន្ទ្រឲ្យច្បាំងគ្នាដោយសុភាសិត គឺបើនរណា និយាយជាធម៌ អ្នកនោះនឹងឈ្នះ; កាលយល់ព្រមគ្នាហើយក៏តាំង គណកម្មការដាក់ខ្ពស់មួយទុកកាត់សេចក្តី ។ ព្រះបាទអសុរិន្ទ្របាន ពោលឡើងថា ៖

"ពួកមនុស្សពាល បើគ្មានគេបង្រ្កាបទេ ក៏មុខជាបះបោរចលាចលវឹកវរមិនខាន ដូច្នេះ អ្នកមានបញ្ញាទើបគួរបង្រ្កាបមនុស្សពាលឲ្យហើយដោយអាជ្ញាយ៉ាងខ្លាំង" ។

ព្រះឥន្ទទូលតបថា ៖

"ខ្ញុំយល់ឃើញថា វិធីការរបស់អ្នកប្រាជ្ញយ៉ាងនេះទៅវិញ គឺបើពាលខ្ទាល់ខ្ទក់ចលាចលឡើង យើងត្រូវមានសតិស្មារតីរម្ងាប់ចិត្តទុកនេះជាគ្រឿងបង្រ្កាបមនុស្សពាល" ។

អ - "លោកកវសរៈ! ខ្ញុំយល់ឃើញទោសនៃការអត់ធន់ដូច្នេះថា: កាលណាជនពាលសំគាល់វិធីការអត់សង្កត់ចិត្តថា ជាការអត់សង្កត់ ព្រោះខ្លាចវាហើយ វាក៏នឹងបានចិត្តឡើងជិះជាន់កាលនោះ ដូចក្នុងទំនងថា "គោបេះតែរត់គេរឹតតែដេញ" ។

ឥ - "ទោះមនុស្សពាលចូលចិត្តថា ការអត់សង្កត់ចិត្តនោះព្រោះខ្លាចវា ឬបែបណាក៏ដោយ ក៏អ្នកជំនាញការឥតអើពើ ។ ព្រោះថាក្បួនប្រយោជន៍ហើយជាកំពូលនៃប្រយោជន៍ខ្លួននោះ គ្មានគុណធម៌ណាក្រៃលែងជាងខន្តីទេ ។ អ្នកដែលមានកំឡាំងខែងរ៉ែង អត់ឱនឲ្យអ្នកទន់ខ្សោយ អ្នកប្រាជ្ញលោកហៅការអត់ធន់នោះថាជាកំពូលនៃខន្តី ព្រោះមនុស្សគ្មានកំឡាំង មុខជានឹងចាញ់ទៅឯង ៗ មិនចាំបាច់ធ្វើអ្វីទេ ។ អ្នកណាមានកំឡាំង ហើយប្រើកំឡាំងដូចមនុស្សពាល អ្នក

ប្រាជ្ញមិនហៅកម្លាំងនៃអ្នកនោះថាបំភ្លួជាកម្លាំងឡើយ លុះតែមានកំម្លាំងហើយ មានធម៌ឃុំគ្រងការពារខ្លួនផង ទើបគ្មាននរណាទឹងចោទបាន ។ មនុស្សក្រោធតបចំពោះអ្នកដែលក្រោធនឹងខ្លួន ត្រឡប់បានឈ្មោះថាជាមនុស្សថោកទាបជាងអ្នកដែលក្រោធចំពោះខ្លួនទៅវិញ ។ មនុស្សមិនក្រោធតបចំពោះអ្នកដែលក្រោធ ចាត់ថាឈ្នះសង្គ្រាមដែលគេឈ្នះបានដោយក្រៃ ។ អ្នកដែលដឹងថាពាលបះបោរចលាចលរំភើរឡើងហើយ មានស្មារតីអត់សង្កត់ចិត្តទុកបាន ឈ្មោះថាធ្វើប្រយោជន៍ដល់ខ្លួននិងអ្នកដទៃបានទាំងពីរចំណែក ។ កាលបើចំណែកយើងនិងចំណែកគេទាំងពីរជាប់ទាក់ទងគ្នាហើយ ក៏ជាការអស់សង្គ្រាម) សូម្បីមនុស្សដែលមិនឈ្លាសក្នុងគន្លងធម៌ នឹងមើលយកតែម្តងថា "ទន់ខ្សោយ" ក៏ដោយ ក៏ឥតជាខសំខាន់អ្វីឡើយ" ។

បរិយោសាននៃការជជែកគ្នាដោយមាត់ គណកម្មការពិចារណាឃើញថា ភាសិតរបស់ព្រះបាទអសុរិន្ទ នាំឲ្យប្រើអាជ្ញា នាំឲ្យចាប់សស្ត្រាវុធ, ញុះញង់ឲ្យគេទាស់គ្នា, ចាក់រុកឲ្យគេឈ្លោះគ្នា. ណែនាំឲ្យគេប្រកួតប្រកាន់ប្រឆាំងនឹងគ្នា ។ ឯភាសិតរបស់ព្រះឥន្ទមិនដឹកនាំឲ្យប្រើអាជ្ញា មិននាំឲ្យចាប់សស្ត្រាវុធ, មិនញុះញង់ឲ្យគេទាស់គ្នា, មិនចាក់រុកឲ្យគេឈ្លោះគ្នា. មិនណែនាំឲ្យគេប្រកួតប្រកាន់ប្រឆាំងនឹងគ្នា ទើប

គាត់សេចក្ដីឲ្យព្រះឥន្ទឈ្មះ ៗ នេះក៏ព្រោះតែយកឈ្នះខ្លួនបានជាមុន នោះឯង ៗ

ដូច្នេះ លោក-អ្នក គួរបេះយកឈ្នះខ្លួនឯង ដើម្បីយកឈ្នះសេចក្ដីអាក្រក់ដែលជាសត្រូវខាងក្នុង របស់ខ្លួនឯង ដោយសេចក្ដីល្អទៅ ដូចយ៉ាងឃាត់ឃាំង ទោសៈ, បណ្ដោះសតិ, ប្រើបញ្ញា, រក្សាធម៌. បង្គាប់ចិត្តខ្លួនឯង, ធ្វើឲ្យខ្លួនមានអំណាចនៅពីលើចិត្ត, ជាធំចំពោះចិត្តខ្លួនរបស់ឯង, មិនបណ្ដោយតាមគាប់ចិត្តរបស់ខ្លួនឯងក្នុងផ្លូវដែលខុស ទីងតាំងចិត្តរៀនឲ្យស្គាល់រឿងធម្មចរិយាទាំងពួង, រៀនឲ្យស្គាល់នាទីចំពោះធម្មជាតិ, គ្រួសារ, មាតាបិតា, ខ្លួនឯង, អ្នកដទៃ ទីងជាតិសាសនា ហើយខំប្រតិបត្តិតាមនាទីនោះៗ ដោយធារហ័សជាដើម, បូជាសេចក្ដីពិត ដូចជានិយាយពិត, ធ្វើពិត, ប្រយ័ត្នខ្លួនឲ្យប្រព្រឹត្តទៅតាមសេចក្ដីពិត, មិនបណ្ដោយខ្លួនឲ្យជាសម្រាមអណ្ដែតទៅតាមខ្យល់, តាមទឹក, ស្មោះត្រង់ចំពោះខ្លួនឯង, មិនកុហកលលួងខ្លួនឯង, ប៉ុន្តែស្រួតែតាមចិត្តខ្លួនឯង, ដឹងថាអ្វីខុស ក៏មិនរកឧបាយមកនិយាយអធិប្បាយពន្យល់កុហកខ្លួនឲ្យឃើញថាត្រូវ, សូម្បីទីងថាអ្វីអាក្រក់ ក៏មិនជំនះធ្វើទៅតាំងបំពាន, ជឿសមត្ថភាពរបស់ខ្លួន ទីងទុកចិត្តខ្លួនឯង, ចាប់របស់ណាធ្វើរបស់នោះឲ្យសម្រេច, ជឿមនុស្សដទៃផងដែរ តែដោយមិនមើលងាយគេ, ជាមនុស្សយុត្តិធម៌, ដាក់ខ្លួនចុះដូចសំពត់ក្រខ្វក់មាស, មិន

យល់ឃើញថាត្រូវ តែទោរទន់ចិត្តក្នុងខណៈ ៗ ដោយសេចក្តីអន្ទូរឡើយ, ផ្ទឹមគំនិតខ្លួននឹងគំនិតអ្នកដទៃ, មិនយល់ឃើញថាខ្លួនសុទ្ធតែប្រសើរគ្រាន់បើគ្រប់យ៉ាង, អប់រំសតិសម្បជញ្ញៈឲ្យបរិបូណ៌, ដម្រង់ជីវិតខ្លួនឲ្យត្រង់ដោយគុណធម៌ដែលមាននៅក្នុងខ្លួនទាំងអស់ និងបង្អោនខ្លួនឲ្យទៅក្រោមសេចក្តីល្អទាំងពួង មិនបានបំភ្លាត់បំផ្លាញរបស់ណាដែលល្អប្រពៃ នេះជាកុសលោបាយ ដែលប្រើសម្រាប់ផ្ចាញ់ខ្លួនឯង និងជាវិធីផ្ចាញ់អធម៌ដោយធម៌ដែលជាការឈ្នះដ៏ប្រសើរក្រៃលែង ។

លោក-អ្នក ចូរយកឈ្នះខ្លួនឯង ដោយវិធីបណ្តុះសំលៀងខ្លួនឲ្យស្រួចមុតដូចមុខសិលា ដែលមានលក្ខណៈមាំទាំខែងរឹងក្នុងខ្លួនឯង និងមានសមត្ថភាពការពារលកដែលបោកបក់សាចចូលមកជានិច្ចចុះ ។ មើលចុះ យើងប្រមៀលថ្មឡើងលើភ្នំ ត្រូវទទួលការនឿយហត់ច្រើនណាស់ តែកាលពន្លែងដុំថ្មចុះមកវិញ ក៏មកដល់ដីក្រោមដោយមិនបាច់ហត់, កម្លាំងចិត្ត បើរឹងប៉ឹងក៏យកឈ្នះខ្លួនឯងបាន បើទន់ខ្សោយក៏ត្រូវចាញ់ខ្លួនឯង ត្រូវរមៀលខ្លួនចុះមកកាន់ទីថោកទាប ដោយមិនបាច់ខ្វល់ខ្វាយជួយប្រមៀលឡើយ "បណ្តាយតាមមួយរយដងប្រសើរជាងការវិវាទមួយដង" នេះជាវិធីការរបស់អ្នកផ្ចាញ់ខ្លួនឯង "សូម្បីគត ហេតុអ្វីក៏វិវាទគ្នាដែរ" នេះជាវិធីការរបស់អ្នកចាញ់ខ្លួនឯង ។ កុំខ្លាចត្រង់ឡើយ! បើយើងបានឈ្នះខ្លួនឯងស្រេចហើយ យើងមុខជាបាន

ទទួលសេចក្ដីល្អប្រពៃនៃនិស្ស័យរបស់យើងពុំបាន សូមខំព្យាយាមជួនទៅចុះ បើមិនដូច្នោះ នឹងទៅជាមនុស្សចាញ់ខ្លួនឯង ៗ មនុស្សចាញ់ខ្លួនឯងនោះ ចូលចិត្តយឹតយោងមនុស្សដទៃក្នុងផ្លូវអាក្រក់ មិនមាននរណាដទៃក្រៅពីខ្លួនមកដឹកនាំទេ កាលខ្លួនដឹកនាំហើយ ខ្លួនក៏ត្រូវធ្វើដែរ កាលការដឹកនាំសម្រេចដោយការធ្វើតាមហើយ ក៏ឈ្មោះថាជាមនុស្សចាញ់ខ្លួន រមែងធ្វើអំពើអាក្រក់ទៅផ្សេងៗ ៗ ហេតុនេះ ត្រូវកុំបណ្ដោយឲ្យចាញ់ខ្លួន គួរយកឈ្នះខ្លួនឯងឲ្យបាន ៗ ព្រោះមនុស្សអ្នករក្សាចិត្តខ្លួនឯងបាន ប្រសើរជាងអ្នកដែលវាយយកស្រុកនគររបស់គេបានទៅទៀត សូម្បីព្រះពុទ្ធជាម្ចាស់ ក៏ទ្រង់ប្រដៅដែរថា មនុស្សឈ្នះខ្លួនឯងម្នាក់ ប្រសើរជាងអ្នកដែលឈ្នះពលទាំងលានក្នុងសង្គ្រាម, គប្បីឈ្នះសេចក្ដីក្រោធដោយសេចក្ដីមិនក្រោធ គប្បីឈ្នះមនុស្សមិនល្អ ដោយសេចក្ដីល្អ គប្បីផ្ចាញ់មនុស្សស្វិតស្វាញ ដោយអធ្យាស្រ័យដ៏ទូលាយ (មិនកំណាញ់), គប្បីផ្ចាញ់មនុស្សនិយាយឡេះឡោះដោយពាក្យពិត ៗ

និស្ស័យកប់អានខ្លួនឯងនេះ ជាគុណសម្បត្តិដែលមានដ៏ថ្លៃខ្ពង់ខ្ពស់ ដាស់ចំណែកលក្ខណធម្មជាតិរបស់ខ្លួនឲ្យភ្ញាក់ឡើង តុបតែងចិត្តឲ្យក្លាហាន មានគំនិតជាន់ខ្ពស់, ដឹកអន្ទងការប្រព្រឹត្តិ ឲ្យដំណើរទៅតាមច្បាប់ធម្មតាខាងល្អ, បំបិទទុកមិនឲ្យគិតទៅតាមច្បាប់ធម្មតាខាងអាក្រក់ ដែលចាត់ថាជាឫសគល់នៃសេចក្ដីល្អទាំងឡាយ នឹងជាទីកើតនៃសេចក្ដីគោរព

រាប់អាននឹងការតបស្នងដ៏មានដម្លៃអំពីមនុស្សដទៃ ។ ព្រោះកាលបើចំណែកម្ខាងគោរពរាប់អានហើយ ចំណែកម្ខាងទៀត ក៏ត្រូវគោរពរាប់អានជាការតបស្នងមកវិញ ។

ដូច្នេះ ទើបគួរអញ្ជើញមកចុះ ! អញ្ជើញមកបណ្តុះនិស្ស័យរាប់អានខ្លួនឯង ដោយវិធីចេះគ្រប់គ្រងខ្លួនឯង, ចេះពឹងខ្លួនឯង, ចេះជឿខ្លួនឯង, ចេះត្រួតត្រាពិនិត្យពិចារណាខ្លួនឯង នឹងចេះយកជ័យជំនះខ្លួនឯង ដូចបរិយាយមកនេះ ។

រឿងការបណ្តុះនិស្ស័យនេះ មិនទាន់ចប់ទេ ប៉ុន្តែសង្ខេបប៉ុណ្ណេះសិន ។
រឿងនេះនឹងមានបោះពុម្ពតទៅទៀត ក្នុងឆ្នាំខាងមុខ ។

## រឿងសាមកុក

### កណ្ឌទី ១៨

### ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នករាជការឆ្លាតបើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

ខណៈនោះ ស្រីដែលស៊ើបការគំរត់ទៅជំរាបចូឆូថា ឥឡូវព្រះចៅហៀនតេត្រាស់ឲ្យហៅតាំងស៊ុនចូលទៅគាល់ · ហើយព្រះរាជទានអាវឲ្យជារង្វាន់ ខ្ញុំឃើញចំឡែកណាស់ ។ ចូឆូឮដូច្នោះក៏ស្រូតចូលទៅក្នុងព្រះបរមរាជវាំង ទទួលជួបនឹងតាំងស៊ុនចេញមកដល់ទ្វារ ក៏សាកសួរថា អ្នកមកពីណា? ។ តាំងស៊ុនឆ្លើយថា មានព្រះរាជឱង្ការហៅខ្ញុំបាទឲ្យចូលទៅគាល់ ហើយទ្រង់ប្រោសព្រះរាជទានអាវនេះឲ្យខ្ញុំបាទ ។ ចូឆូសួរថា ដែលទ្រង់ប្រោសព្រះរាជទានអាវនេះ អ្នកមានបំណាច់អ្វី? ។ តាំងស៊ុនឆ្លើយថា ទ្រង់ព្រះដំរិះរលឹកឃើញកាលគ្រាខ្ញុំបាទនាំស្ដេចរត់ចេញ ពីចំណោមលីឈុយគុយគី ។ ចូឆូបាន

ព្ទដូប្រោះក៏ពីការល់ក្នុងចិត្ត ទើបធ្វើជានិយាយថា អ្នកមានគុណបំណាច់ មែន បានប្រោសព្រះរាជទានអាវនេះ បើដូច្នេះចូរដោះមកឲ្យយើងពាក់ លមើលបន្តិច ។ តាំងស៊ុនបានឮដូច្នោះក៏ភ័យស្លុតចិត្ត សម្ងំស្ងៀម មិនព្រមដោះអាវនោះ ។ ប៉ូធួយឃើញតាំងស៊ុនធ្វើព្រងើយដូច្នោះ ក៏មាន សេចក្ដីសង្ស័យ ទើបប្រើឲ្យទាហានបង្ខំដោះអាវមកពិនិត្យមើល ក៏មិន បានឃើញជាប្លែក ក៏យកអាវនោះទៅពាក់ហើយធ្វើជាសើចថា អាវនេះ សមគួរតែខ្លួនយើង អ្នកឲ្យយើងទៅចុះអ្វី? ។ តាំងស៊ុនតបថា អាវ នេះជារបស់ព្រះរាជទាន ដែលខ្ញុំបាទទទឹងជូនទៅលោកនោះមិនគួរ បើ លោកត្រូវការប្រាថ្នាហើយនឹងយកទុក ក៏តាមចិត្តលោកចុះ ។ ប៉ូធួតប ថា "យើងនឹងប្រាថ្នាយកមកធ្វើអ្វី អាវយ៉ាងនេះ" ហើយក៏ដោះ ប្រោះឲ្យទៅតាំងស៊ុនវិញ តាំងស៊ុនក៏លាប៉ូធួទៅផ្ទះ ។

លុះវេលាយប់តាំងស៊ុនចូលទៅក្នុងទីដំណេកម្នាក់ឯង យកអាវនោះ មកពិនិត្យមើលសព្វគ្រប់ ក៏ឃើញព្រែសនៅក្នុងជាយស្រទាប់ហែកចេញ មកមើលឃើញជាឡាយព្រះហស្តលេខា នៃព្រះចៅហៀនតេទ្រង់លិខិត ដោយលោហិតជាសេចក្ដីថា "តាំងពីប៉ូធួចូលមកនៅក្នុងស្រុកក្រុងបាន ៤ ឆ្នាំហើយ ធ្វើការអាក្រក់ផ្សេង ៗ បំពារលើព្រះរាជអាជ្ញា នឹងតាំង ចិញ្ចឹមនាម៉ឺនខ្ញុំរាជការ ឬចុះទោសអ្នកឯណាក៏តាមអំពើចិត្ត មិនមាន សេចក្ដីគិតៈកាតក្រែងព្រះបេស្កាបារមី មិនយកសេចក្ដីក្រាបទូលស្មើឲ្យ

ទ្រង់ប្រជាប ឈុះតែយើងអត់ទ្រាំពុំបាន ទើបចាក់យកព្រះលោហិតក្នុងម្រាមព្រះហស្ត លិខិតជាសេចក្ដីអាថ៌កំបាំងទ្រង់ព្រះរាជទានមក បើតាំងស៊ុនយល់ឃើញមន្ត្រីរាជការឯណា មានសតិបញ្ញាទៀងត្រង់នឹងផែនដី ក៏បបួលមន្ត្រីនោះមកជាគូរះគិតកំចាត់ចួចជាសត្រូវរាជសម្បត្តិឲ្យខ្ចាត់វិនាសចេញ ទើបយើងនឹងអាណាប្រជារាស្ត្រទាំងពួងនឹងបានអស់ទុក្ខទោមនស្សនៅជាសុខក្សេមក្សាន្តទៅ ។

តាំងស៊ុនឃើញឡាយព្រះហស្តដូច្នោះ ក៏មានសេចក្ដីអាណិតអាណាចក្នុងចិត្តពន់ពេកណាស់ អន្ទយយំខ្សឹកខ្សួលតែម្នាក់ឯងចម្បែងចិត្តគិតមិនសុខសាប់ តាំងពីព្រលប់យប់យូរស្ងាត់លុះដល់ព្រឹក ដេកមិនលក់សោះ លុះព្រឹកឡើងក៏កាន់ឡាយព្រះហស្តនោះចូលទៅក្នុងបន្ទប់សរសេរ ប្រះខ្នងផ្អែកចុះលើកៅអី មើលសេចក្ដីបុតហ្វាយនោះទៀតក៏ខំត្រិះរិះទៀតនឹងរកឧបាយសម្លាប់ចួចឲ្យបាន លុះគិតទៅគិតមកក៏មិនឃើញមានផ្លូវត្រង់ណា ទើបយកឡាយព្រះហស្តនោះមកសិកទុកក្នុងដៃអាវ ដោយកំឡាំងវេលានៀយហត់អត់ងុយណាស់ ក៏ផ្ទេសលក់លើកៅអីនោះ ។

ខណៈនោះដូហុកជាមន្ត្រីរាជការ ជាមិត្តភក្ដិនឹងតាំងស៊ុនធ្លាប់ទៅមករកគ្នាជានិរន្តរ៍ ក៏ចូលទៅឃើញព្រះសុកអក្សរនៅដៃអាវតាំងស៊ុនដែលកំពុងដេកលក់នោះ បានគន់មើលមុខមាត់ក៏ឃើញសៅហ្មងគងដៃលើ

ដើមទ្រូង ជូហ្កកក៏ហូតយកលិខិតនោះមកលាមើល ឃើញថាឡាយព្រះហស្ដព្រះចៅហ្វៀនគេទ្រង់សរសេរដោយព្រះលោហិត ដាក់សេចក្ដីល្អិតក្នុងសំបុត្រនោះ គឺឲ្យតាំងស៊ុនគិតសម្លាប់ចូឆូចេញ ជូហ្កកក៏យកឡាយព្រះហស្ដនោះមិញលាក់ស៊កទុកក្នុងដៃអាវរបស់ខ្លួន ហើយក៏ដាស់តាំងស៊ុនឲ្យភ្ញាក់ឡើងនិយាយថា ហេតុម្ដេចក៏មកមានសេចក្ដីសប្បាយដេកលក់ដូច្នេះ ៗ តាំងស៊ុនភ្ញាក់ឡើងពរកឡាយព្រះហស្ដមិនឃើញក្នុងដៃអាវក៏ភ័យស្មាំងកាំង ៗ ជូហ្កកឃើញដូច្នោះក៏វិក្កនិយាយថា អ្នកទីងគិតប្រទូសរ៉ាយចូឆូឬ? យើងនឹងទៅប្រាប់ចូឆូឲ្យដឹង ៗ តាំងស៊ុនបានស្ដាប់ជូហ្កកនិយាយដូច្នោះ ក៏រឹតតែភ័យពន់ប្រមាណ ស្មានមើលទៅដូចទីងរលត់ជីវិតសូន្យសោះ ហើយថា បើអ្នកនឹងទៅប្រាប់ចូឆូនោះមិនមែនស្លាប់តែខ្លួនយើងមួយទេ បីដូចជាអ្នកធ្វើឲ្យក្ស័យព្រះជន្មព្រះចៅហ្វៀនគេផង ៗ ជូហ្កកឆ្លើយថាអ្នកកុំវិតក្កទុក្ខព្រួយឡើយ ខ្ញុំចង់ដឹងហើយទើបពិសោធចិត្តអ្នកមើល ខ្លួនខ្ញុំក៏ជាខ្ញុំក្រោមព្រះបាទព្រះចៅហ្វៀនគេសព្វថ្ងៃខ្ញុំក៏តាំងចិត្តសុចរិត នឹងធ្វើពលការបំរាយស្នងព្រះគេជព្រះគុណជាដរាប តែថោកទាបសំណាងនឹងរកនរណាជួយគិតជាចារិកបង្គោលគ្មាន ឥឡូវបើអ្នកនៅមានគំនិតគិតទីងរំលាងសត្រូវរាជសម្បត្តិ ដូចគំនិតខ្ញុំដែរ យើងទាំង ២ ត្រូវយកកាសាផែនដីរួមសេចក្ដីគិតជាមួយគ្នាទៅ ៗ តាំងស៊ុនបានស្ដាប់ក៏កើតត្រឡប់ចិត្តរីករាយសប្បាយណាស់

ទើបថា បើអ្នកតាំងចិត្តសុចរិតត្រង់នឹងផែនដីមែន ខ្ញុំយល់ឃើញថា ព្រះចៅហៀនគេគង់នៅមានព្រះបារមីតេជៈឈ្នះបច្ចាមិត្រជាប្រាកដ ។ ជូហុកថា ខ្ញុំនឹងអ្នកបើនឹងចាប់គិតទំនុកបំរុងផែនដីហើយ ត្រូវតែធ្វើសំបុត្រចុះសញ្ញាគ្នាជាសំគាល់ ទើបនឹងបានតាំងចិត្តគិតការតទៅ ។ ខណៈកាលកំពុងនិយាយគ្នានោះ មានមនុស្សចូលទៅប្រាប់តាំងស៊ុនថា គាត់អ៊ុបទឹងផ៉ៅហួនមានការមកសុំជួប ។ តាំងស៊ុនបានឮដូច្នោះមានចិត្តត្រេកអរនិយាយនឹងជូហុកថា គាត់អ៊ុបទឹងផ៉ៅហួននេះជាគៀនសំឡាញ់ខ្ញុំដែរ បើដូច្នេះចូរអ្នកចូលទៅអែបនឹងកាំងននពីក្នុងសិនចុះ ខ្ញុំនឹងឲ្យហៅគេចូលមក ។ តាំងស៊ុនក៏ឲ្យគេទៅអញ្ជើញចូលមក អ្នកទាំង ២ នាក់ចូលមកហើយ ក៏គំនាប់គ្នាតាមទម្លាប់ហើយគាត់អ៊ុបនិយាយថា កាលព្រះចៅហៀនគេស្តេចទៅប្រពាតព្រៃ ចូចូក់ធ្វើល្មើសនឹងព្រះចេស្តាជាការអាក្រក់ខ្លាំងណាស់ អ្នកមានចិត្តក្តៅខ្លះដែរឬទេ? ។ តាំងស៊ុនថា ខ្ញុំក៏ឃើញច្បាស់នឹងភ្នែកហើយ តែមិនដឹងនឹងធ្វើដូចម្តេច? ។

ផ៉ៅហួនថា ធម្មជាតិដែលកើតមកជាប្រុសហើយ ៗ បានមកនៅជាខ្ញុំរាជការ ទោះបីអាយុសង្ខារនឹងស្លាប់ក៏ពុំត្រូវសោកស្តាយ ត្រូវខ្វល់ខ្វាយជួយយកអាសាផែនដីឲ្យបានសេចក្តីសុខសប្បាយ ដើម្បីទុកនាមឈ្មោះទៅមុខ ។ ជូហុកដែលអែបនៅក្នុងកាំងនន ឮដូច្នោះក៏ស្ទុះចេញមកនិយាយនឹងតាំងស៊ុនថា អ្នកសូមធ្វើជាបន្ទាល់យើងផងចុះ ព្រោះ

វេលានេះគាន់អ៊ុបទឹងនៅហ៊នគិតគ្នានឹងប្រពន្ធ ខ្ញុំនឹងនាំយក សេចក្ដីនេះទៅជំរាបបពិត្រឲ្យដឹង ។ គាន់អ៊ុបបានស្ដាប់កន់កទឹងឆ្លើយថា កើតមកជាខ្ញុំផែនដីត្រូវតែមានសេចក្ដីកតញ្ញូនឹងព្រះមហាក្សត្រ មិនត្រូវ គោតខ្លាចក្រែងជីវិតនឹងអន្តរាយទេ ។ តាំងស៊ុនក៏ហាមឃាត់គាន់អ៊ុបថា "អ្នកកុំអាលខឹងប្រទេ្យតឡើយ ការណ៍ទាំងអស់នេះខ្ញុំបានគិតហើយនឹង ដូហ៊ុកព្រមចិត្តគ្នាមួនអ្នកទាំង ២ ទៅទៀត បានជាខ្ញុំមកធ្វើតប្រឹក្សានឹង អ្នកជាក្រោយ ឯដូហ៊ុកនិយាយនេះ ដើម្បីពិសោធចិត្តអ្នកល្បងមើល ទេ" ហើយតាំងស៊ុនក៏យកឡាយព្រះហស្ដលេខាហុចឲ្យគាន់អ៊ុបទឹង នៅហ៊នមើល ។ គាន់អ៊ុបទឹងនៅហ៊នឃើញច្បាស់ជាឡាយព្រះហស្ដក៏ ស្រក់ទឹកភ្នែកយំយែក ទឹកអាណិតព្រះចៅហៀនតេពន់ពេកណាស់ ។

ដូហ៊ុកនិយាយថា អ្នកទាំង ២ នៅជាមួយនឹងតាំងស៊ុនចុះ ខ្ញុំសុំទៅ ហៅដូឡានមកជួបទៀត ដូហ៊ុកក៏ចេញទៅហៅដូឡានចូលមក ហើយ យកឡាយព្រះហស្ដបង្ហាញឲ្យមើល ទើបគិតព្រមព្រៀងគ្នាចុះឈ្មោះ ទុកកងសេចក្ដីសញ្ញាទាំង ៥ នាក់ ។ តាំងស៊ុនក៏ឲ្យរៀបតុលាងស៊ុរា ហើយសច្ចាប្រណីធានចំពោះមុខគ្នាទៅវិញទៅមក គឺថាមិនបានយក សេចក្ដីនោះទៅបរិហារឲ្យលេចព្ភតទៅ ។

ម៉ាថេងចៅហ្វាយស្រុកសេលៀងដែលចូលមកកងស្រុកក្រុង កាល ព្រះចៅហៀនតេស្ដេចទៅប្រពាធព្រៃនោះ ក៏បានហែស្ដេចទៅដែរ

ម៉ាថេង់ឃើញចូចូធ្វើកិរិយាប្រមាថមើលងាយព្រះចេស្តា ក៏មានសេចក្ដីឈឺចិត្តគិតទោមនស្សខ្លាំងណាស់ ។ មានថ្ងៃមួយម៉ាថេង់ទៅរកតាំងស៊ុនឯផ្ទះ ។ អ្នកចាំទ្វារចូលទៅជំរាបតាំងស៊ុនថា ម៉ាថេង់មានការមករកលោក ។ តាំងស៊ុនកំពុងអង្គុយផឹកស្រាជាមួយនឹងមន្ត្រី ៤ នាក់ លុះបានឮដូច្នោះក៏ភ័យណាស់ បង្គាប់ឲ្យលើកយកតុះលៀងចេញ ហើយឲ្យមន្ត្រី ៤ នាក់អែបលាក់ខ្លួនកង់ឆាក រួចក៏ក្រោកចេញទៅទទួល ។ ម៉ាថេង់ក៏គំនាប់តាមសមគួរ ក្រឡេកឃើញទឹកមុខតាំងស៊ុននៅមានឈាមស្រស់ថ្លាក៏សំគាល់ថាតាំងស៊ុនមិនមានឈឺចិត្តនឹងផែនដីក៏តូចចិត្ត ទើបថា "ខ្លួនអ្នកជាមន្ត្រីព្រះចៅហៀនតេទ្រង់កប់អានថាជាព្រះញាតិវង្ស ហេតុម្ដេចអ្នកមិនមានឈឺចិត្តនឹងការផែនដីសោះ" ថាហើយក៏គំនាប់ប្រឹងនឹងលាត្រឡប់ទៅវិញ ។ តាំងស៊ុនពីកាលកុងចិត្តក៏ចាប់ដាយអាវឲ្យឈប់ហើយថា ហេតុម្ដេចបានជាអ្នកថាយើងមិនឈឺចិត្តនឹងការផែនដី? ។ ម៉ាថេង់តបថា កាលព្រះចៅហៀនតេស្ដេចយាងទៅប្រពាតព្រៃ ចូចូធ្វើកិរិយាប្រមាថមើលងាយព្រះចេស្តា យើងជាខ្ញុំរាជការខាងក្រៅក៏គង់មានចិត្តឈឺចាប់ ចុះអ្នកជាពូជព្រះញាតិវង្សព្រះចៅហៀនតេស្រាប់ ហេតុម្ដេចមកនៅសប្បាយដូច្នេះ មិនគិតកំចាត់សត្រូវរាជសម្បត្តិចេញទេឬ? ។

(មានត)

# នាលះ និង ទមយន្តី

រឿងព្រេងប្រទេសឥណ្ឌា

## អ្នកស្រីស្រិន-សារយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

### វគ្គទី ៩

ព្រះបាទនាលៈទ្រង់ស្តេចត្រឡប់ទៅទូលអាទិទេពវិញតាមដំណើររបស់ខ្លួនដោយគ្មានលាក់បំណងរបស់ព្រះនាងទមយន្តីផង ។ អាទិទេពញញឹមហើយក៏ព្រមព្រៀងទៅឯប្រទេសវិទភៈជាមួយនឹងព្រះបាទនាលៈ ។

គេបានឲ្យអាទិទេព នឹងព្រះមហាក្សត្រទាំងឡាយចូលទៅក្នុងបន្ទប់មួយខ្ពស់ដែលមានជញ្ជាំង សសរ នឹងពិតានរំលេចដោយមាសនឹងត្បូងពេជ្រដ៏ភ្លឺរន្ទាលព្រោងព្រាត ។ ព្រះបាទភិមៈទ្រង់គង់នៅចាំទទួលព្រះមហាក្សត្រ ដែលមានព្រះរាជបំណងចង់បានព្រះរាជបុត្រីទ្រង់ធ្វើជាឯកអគ្គមហេសី ។ ចំពោះព្រះមហាក្សត្រមួយអង្គ ៗ មហារាជទ្រង់ទទួលដោយព្រះទ័យរាក់ទាក់ ដើម្បីនឹងលើកទឹកព្រះទ័យនៃក្សត្រទាំងនោះ ។ ព្រះរាជាមានព្រះហឫទ័យរីករាយពន់ពេកណាស់ ពីព្រោះទ្រង់យល់ថាបណ្តាស្តេចដែលមានកេរ្តិ៍ល្បីនៅលើដីទាំងនោះ មុខតែព្រះរាជបុត្រីទ្រង់ជ្រើសយកណាមួយជាស្វាមី ដែលសមស័ក្តិនឹងព្រះនាងមិនខាន ។

ព្រះពជាទ្រង់ធ្វើការកិច្ចយ៉ាងប្រសើរចំពោះអាទិទេព ព្រះអង្គទ្រង់មានព្រះទ័យធ្លាក់ចុះពេកដោយឃើញអាទិទេពមកដែរ ៗ លុះស្ដេចទាំងអស់ឃើញព្រះបាទនាលៈ ទ្រង់យាងមកដល់ កំកើតសេចក្ដីអស់សង្ឃឹមក្នុងការបានព្រះនាងទមយន្តីជាភរិយា ៗ

មហាក្សត្រទាំងអស់គង់លើព្រះទីនាំងខ្ពស់ៗ ហើយព្រះបាទភិមៈទ្រង់ប្រើបំរើឲ្យទៅទូលព្រះនាងទមយន្តី ៗ ព្រះនាងយាងចេញមកដោយមានកាន់កំរងផ្កាឈូក ១ ផង ដើម្បីនឹងពាក់ឲ្យក្សត្រណាដែលព្រះនាងសព្វព្រះហឫទ័យនឹងយកជាស្វាមី ៗ ក្សត្រទាំងប៉ុន្មានទាំគ្នាប្រមូលភ្នែកទៅលើព្រះនាងទាំងអស់ ស្ទើរតែពុំហានដកដង្ហើម ក្នុងបន្ទប់នោះស្ងាត់ស្ងៀប ៗ ព្រះនាងទ្រង់ស្ដេចយាងសន្សឹមៗ ហើយនឹកថា អញបំណាំព្រះភក្ត្រព្រះបាទនាលៈបានហើយ ៗ ប៉ុន្តែបន្តិចមកស្រាប់តែព្រះនាងសង្ស័យជាខ្លាំងហើយបើកព្រះនេត្រធំ ៗ សំឡឹងទៅតែជួនម្នាងដែលព្រះនាងទតឃើញស្ដេចជាច្រើនរូបមានព្រះភក្ត្រដូចជាព្រះបាទនាលៈ ៗ លុះមួយស្របក់ព្រះនាងនឹកឃើញថា "នេះជាកលឧបាយនៃព្រះអាទិទេពដែលជំនែងធ្វើឲ្យដូចជាព្រះបាទនាលៈទេតើ, ទោះជាយ៉ាងណាក៏ដោយ ក៏អញមានប្រាថ្នាតែលើរូបព្រះបាទនាលៈប៉ុណ្ណោះ" ៗ កាលនោះ ព្រះនាងក៏បួងសួងថា: "ឱអាទិទេព! ខ្ញុំម្ចាស់បានឮសំដីក្បានខ្ញុំម្ចាស់មានប្រាថ្នាតែលើរូបព្រះបាទនាលៈ ១ ទេ, ខ្ញុំម្ចាស់ស្រឡាញ់

ទ្រង់ ហើយមានចិត្តត្រង់នឹងទ្រង់ផង; ឱព្រះគុណថ្លៃឧត្តមអើយ ! សូមឲ្យខ្ញុំម្ចាស់ស្គាល់ថា ណាមួយ ស្តេចនាលៈ, ទុកជាយ៉ាងណាក៏ដោយខ្ញុំម្ចាស់មិនលះបង់ទ្រង់នាលៈឡើយ សូមទ្រង់មេត្តាបង្ហាញខ្ញុំម្ចាស់ឃើញឲ្យច្បាស់, សូមអាទិទេពទាំងប៉ុន្មានត្រឡប់យករូបរបស់ខ្លួនវិញ ដោយសេចក្តីអំពាវនាវរបស់ខ្ញុំម្ចាស់ សូមទ្រង់មេត្តាបង្ហាញព្រះបាទនាលៈឲ្យខ្ញុំម្ចាស់ឃើញឲ្យច្បាស់ ខ្ញុំម្ចាស់ស្រឡាញ់ទ្រង់ហើយមានចិត្តត្រង់ចំពោះតែរូបទ្រង់មួយទេ" ។

លុះបានឮសំដីបួងសួងរបស់ព្រះនាងដូច្នេះហើយ អាទិទេពក៏យល់ថា គ្មានអ្វីនឹងអាចបំបែរបំណោងព្រះនាងបានឡើយ ទ្រង់យល់នូវសេចក្តីស្នេហានៃព្រះនាងដែលខ្ជាំងក្រៃលែង ហើយជួយសំរេចសេចក្តីប្រាថ្នារបស់នាង ។ អាទិទេពក៏និមិត្តខ្លួនឲ្យអណ្តែតផុតពីដី ហើយមានភ្នែកនឹងថ្កល់, ចំណែកព្រះបាទនាលៈមានព្រះបាទជាប់នឹងដី ហើយពព្រិចព្រះនេត្រ នៅកង់កណ្តាលអាទិទេព ។ ព្រះនាងទមយន្តី កើតសេចក្តីរីករាយឡើង ហើយទ្រង់យាងដោយញញើតផង យកផ្កាកំរងទៅពាក់ថ្វាយព្រះបាទនាលៈ ។

* * *

## វគ្គទី ១០

ក្នុងខណៈនោះ មានតែអាទិទេពទេដែលសំដែងសេចក្តីរីករាយមុនគេ ។ ពួកស្តេចក្រៅពីនោះ ដាក់ព្រះភក្ត្រចុះបែបអៀនខ្មាស ប៉ុន្តែ

ស្តេចទាំងនោះសឹងផ្ទាប់ថា នៅចំណោមស្តេចទាំងអស់ គ្មានស្តេចណាមួយល្អស្មើព្រះបាទនាលៈទេ ។ ព្រះបាទភិមៈទ្រង់សោមនស្សនឹងព្រះរាជសុណាសារក្រៃពេក ។ ព្រះបាទនាលៈទ្រង់មានព្រះបន្ទូលដោយព្រះរាជាស្រទន់ទៅកាន់ព្រះនាងទមយន្តីថា " ឱព្រះនាងដ៏ប្រសើរ! ចុះបើនៅក្នុងចំណោមអមតកៈបុរស (Immortel) ព្រះនាងរើសយកមតកៈបុរស (mortel) ជាស្វាមីហើយ ខ្ញុំក៏នឹងធ្វើតាមបង្គាប់ព្រះនាងដោយសេចក្តីរីករាយ, ឱទមយន្តី ក្សត្រីដ៏មានព្រះកក្តញ្ញូញ៉ឹមស្រស់អើយ! ព្រះនាងគង់ព្រះជន្មនៅដរាបណា ខ្ញុំមានចិត្តស្មោះត្រង់តែលើរូបព្រះនាងមួយដរាបនោះ" ។ ព្រះនាងទមយន្តីធ្វើគារវកិច្ចចំពោះព្រះអគ្គី ហើយមានព្រះបន្ទូលតបថា: "ខ្ញុំម្ចាស់មានចិត្តស្នេហាព្រះអគ្គីជាអង្គផ្ទង់ណាស់មកហើយ ត្រូវតែខ្ញុំម្ចាស់គោរពព្រះអគ្គីវិញទេ ដោយការប្រព្រឹត្តតាមប្រវេណីជាឯកអគ្គមហេសីចិត្តស្មោះ, ខ្ញុំម្ចាស់នឹងមានសេចក្តីស្នេហាតែលើព្រះអគ្គីជានិរន្តរ៍ ហើយខ្ញុំម្ចាស់នឹងទៅតាមព្រះអគ្គីជានិច្ច ទោះជាទៅទីកន្លែងណាក៏ដោយ" ។ ក្សត្រទាំងពីរនាំគ្នាបែរព្រះភក្ត្រនោះទៅរកព្រះឥន្ទ្រ ព្រះអគ្គី និងអាទិទេពឯទៀត ហើយព្រះនេត្រក្សត្រទាំងពីរអង្គនេះហាក់ដូចជាអង្វរសូមឲ្យអាទិទេពទាំងនេះជួយទ្រទ្រង់ព្រះអង្គ ។ ព្រះឥន្ទ្រក៏មានព្រះបន្ទូលឡើងថា "យើងមិនបោះបង់ឯងទេ នាលៈ! ចូរឯងរក្សាសេចក្តីក្លាហាននឹងសន្តិភាពជានិច្ចចុះ, ចូរព្រះនាងទមយន្តី

ក្បាននូវសេចក្ដីសុខត្រង់នុំងសុខុមចិត្ត, សូមក្សត្រទាំងពីរទ្រង់គង់នៅជាសុខ ក្សេមក្សាន្តរហូត ដែលសម្បូរដោយផ្កាយ៉ាងបរិសុទ្ធ" ។ ព្រះអាទិទេព ទ្រង់ឲ្យពរសព្ទសាធុការស្រេចកាលណា គំហោះឡើងនៅកាន់ស្ថាន សួគ៌ទេវលោកវិញតាមលំដាប់ ។ ឯស្ដេចទាំងឡាយពោះមិនបានសម្រេច បំណងរបស់ខ្លួនក្ដី ក៏ឲ្យពរសព្ទសាធុការយ៉ាងវែង ៗ ចំពោះព្រះបាទ នាលៈនឹងព្រះនាងទមយន្តីដែរ ។ ព្រះបាទភិមៈទ្រង់ចង់ឲ្យរៀបអភិសេក ព្រះរាជបុត្រី នឹងព្រះបាទនាលៈយ៉ាងឆាប់ មិនបង្អង់ឲ្យយូរការ ។

*
* *

វគ្គទី ១១

ព្រះបាទនាលៈនឹងព្រះនាងទមយន្តី គង់នៅជាសុខសាន្តក្នុង ប្រទេសព្រះបាទភិមៈ ។ ទ្រង់មានសេចក្ដីស្នេហារកគ្នាមិនចេះអស់ មិនចេះហើយ ។

ប៉ុន្តែបន្ទាប់ពីថ្ងៃប្រជុំសន្និបាតមក ឆ្មាំទ្វារម្នាក់បានមកក្រាបបង្គំទូល ព្រះបាទភិមៈថា មានបុរសម្នាក់មានមុខមាត់អាក្រក់ ដើរចូលមកដល់ មាត់ទ្វារព្រះបរមរាជវាំង ។ ឆ្មាំទ្វារថាគេបានឃាត់ហើយសួរថាៈ "ឯងទៅណា អ្នកណា?" ។ ជាពួកឆ្មាំនាំគ្នាស៊ើបចំអកថាៈ "ឯងទៅ ទីសន្និបាតឬ?" ។ ជាក់ឆ្លើយថា "ខ្ញុំបាទទៅឯទីសន្និបាត" ។

— ហួសពេលទៅហើយសំឡាញ់! គេលើកលែងប្រជុំតាំងតែពីថ្ងៃម្សិលម៉្ងេះ ម្យ៉ាងទៀតបើទុកជានៅប្រជុំក៏គេមិនឲ្យឯងចូលទេ"

— ម្តេចក៏គេមិនឲ្យខ្ញុំចូល បើខ្ញុំជាអាទិទេព? ។

— អ្នកឯងជាអាទិទេពឬ? ។

— ហ្នឹងហើយខ្ញុំជាអាទិទេព, ជាអាទិទេពដែលគេត្រូវតែខ្លាចផង, យើងអាចធ្វើឲ្យកើតសម្បត្តិធនធាន ឬសេចក្តីលំបាកគោកយាក បានតាមទំនើងចិត្ត ។

— ពួកឆ្មាំទ្វារបានឮដូច្នេះ រឹតតែសើចខ្លាំងឡើងទៀត ហើយនិយាយបញ្ឆោះថា: "នែសំឡាញ់! ពីម្សិលមិញអាទិទេពមកទាំងអស់ ប៉ុន្តែគ្មានអង្គណាមួយមានរូបដូចអ្នកឯងទេ" ។

— តើព្រះមហាក្សត្រី រើសយកអាទិទេពណាមួយជាស្វាមី? ព្រះឥន្ទ្រាធិរាជ, ព្រះអគ្នី ឬព្រះវរុណ? ។

— ព្រះនាងរើសយកព្រះបាទនាលៈជាស្វាមី ។

— ព្រះនាងធ្វើបញ្ឆោះឲ្យអាទិទេព, មិនអីទេយើងចេះដាក់ទណ្ឌកម្មដល់ព្រះនាងនិងព្រះបាទនាលៈ, យើងនឹងសងសឹកជំនួសអាទិទេព ។ បុរសអាក្រក់នោះ ក្រោយពីបានពោលពាក្យបំភ័យដូច្នេះហើយ ក៏ទៅបាត់ទៅ ។

(មានត)

---

# ៣ — ដំណើរទៅកាន់ឧត្តរិមនុស្សធម្មប្រទេស

(Pays de Parade)

លោកកាំស្ទីយ៉ូយេ បានសិក្សានូវគោលការណ៍នៃជីវិតនឹងសេចក្ដីស្លាប់ក្នុងអមតប្រទេស ហើយនឹងទិដ្ឋភាពផ្សេងៗនៃទុគ្គតភាព នឹងសេដ្ឋភាព នៅសម្បូណ៌ប្រទេស ។ លោកទៅជាមានចិត្តឧបេក្ខាបំពោះសេចក្ដីស្លាប់ ហើយការមានទ្រព្យសម្បត្តិ លោកគ្មានបំណងចង់បានអ្វីសោះឡើយ ។ ក្នុងថ្ងៃមួយលោកជិះក្រសារហោះចេញពីសម្បូណ៌ប្រទេសចម្ងាយប្រហែល ២០ ពាន់យោជន៍ ស្រាប់តែលោកក្រឡេកទៅឃើញទីក្រុងមួយដែលលោកស្មានថាជាព្រះរាជធានីនៃប្រទេសមួយធំ ។ មានវិថីមួយល្អចូលទៅកាន់គេហដ្ឋានមួយ ដែលលោកបានឃើញមនុស្សប្រុសស្រីជាច្រើន មានមុខលាបម្សៅផាត់ពណ៌ សួរលោកថា: "អញ្ជើញមកពីណា" ។ លោកបានឆ្លើយតបទៅវិញថា: "ខ្ញុំមកពីប្រទេសជប៉ុន" ។ អ្នកម្ចាស់ផ្ទះបានពុតពាក្យដូច្នោះ ធ្វើឫកក្រអឺត

ក្រទមហើយពោលតបមកវិញថា: "ខ្ញុំបានឃើញប្រទេសតូចៗ ដូចជាប្រទេសជប៉ុន, ប្រទេសចិនហើយនិងប្រទេសឥណ្ឌូ; តែប្រទេសដែលលោកអញ្ជើញមកដល់នេះគេហៅថា "ឧត្តរិមនុស្សធម្មប្រទេស" ជាប្រទេសឧត្តមក្នុងពិភពលោក, ប្រជារាស្ត្រនៅក្នុងប្រទេសនេះ ជាបុគ្គលប្រកបដោយសុក្រិតភាព ចេះដឹងខាងអក្សរសាស្ត្រហើយនិងបុកសង្ហា តើអ្នកអាចអញ្ជើញទៅលេងឯគេហដ្ឋានរបស់ខ្ញុំបានឬទេ?" ។

ដល់លោកចូលទៅក្នុងបាហុនស្ថាន លោកបានឃើញកាព្យនិទានផ្សេងៗ ហើយនិងគំរូនៃអក្សរស្អាតល្អព្យួរលើជញ្ជាំង, ចំណែកខាងឧទ្យានគេបានឃើញនូវរុក្ខជាតិ មានទ្រង់ទ្រាយល្អសមរម្យ និងចង្កៀងគោមធ្វើពីថ្ម ៗ ហើយវត្ថុទាំងអស់នោះ ធ្វើឲ្យលោកសប្បាយចិត្តពន់ពេក ។ ដល់បន្ទប់ទៀត មានអ្នកស្រីម្នាក់ជាម្ចាស់ផ្ទះ មានអាយុជាងសាមសិបឆ្នាំអញ្ជើញមកដល់ ។ អ្នកស្រីនេះពាក់អាវវែងធ្វើពីសំពត់សូត្រប៉ាក់ឌិនមាស, ហើយក៏ដើងដាក់រំយោលសំយុងចុះ កំរើកដៃក្រអូបឈ្ងុយឈ្ងប់ហើយញាក់ស្មា, ពោលពាក្យស្រទន់ផ្អែមថា:

"អ្នកជាជនបរជាតិដ៏ឧត្តម! សូមលោកទទួលនូវកិត្តិយសស្និតនៅក្នុងគេហដ្ឋានខ្ញុំអស់កាលយូរ, ដើម្បីកុំឲ្យលោកអផ្សុក ខ្ញុំនិងតាំងខ្លួនខ្ញុំជាអ្នកណែនាំក្នុងពិធីបុណ្យ ទទួលតែថ្លែងនូវបសំសកថា ក្នុងពេលសូត្រកវីនិពន្ធនិងលេងភ្លេងមហោស្រព, ខ្ញុំបានឮថា នៅប្រទេសនេះ

មានវិញ្ញូជនក្នុងអតីតកាលធ្លាប់ទៅប្រទេសជប៉ុន ហើយខ្ញុំពេញចិត្តដ៏ពន្លឹកចំពោះអក្សរសាស្ត្រ; ខ្ញុំចូលចិត្តខាងកាព្យនិទាននិងប្រលោមលោកនិពន្ធ (Momens)" ។ អ្នកស្រីពោលពាក្យយ៉ាងនេះផង, ក្រឡេកមើលទៅពពកអណ្តែតលើនភាល័យ ហើយឈប់ញញឹមទៅវិញ ។ លោកក៉ស៊ូប៊ីយូយេយល់ថាស្ត្រីនេះជាស្ត្រីគួរឲ្យកោតខ្លាច ក៏ភ័យតក់ស្លុតពន់ពេក ហើយខ្លួនលោកមិនបានស្ថិតនៅនឹងខ្លួន ដូចជានាងទាសីមកថ្លែងរឿងប្រាប់នាយចៅហ្វាយ ។ លោកពោលទៅកាន់អ្នកស្រីថា "អ្នកស្រី! ខ្ញុំបាទជាអ្នកល្ងង់ខ្លៅហើយខ្ញុំគ្មានចំណេះអ្វីជាសុក្រិតទេ ។ ក្នុងពេលនោះ លោកបានឃើញអាវវែងអ្នកស្រីធ្វើពីសូត្រនោះ ជាសូត្ររចនាដោយក្បូងក្បាយ ៗ

ដល់អ្នកស្រីចេញពីទីនោះ ទៅសម្រាកកំឡាំង លោកបានឃើញស្រីនេះនៅទីផ្ទះបាយ (អគ្យាគារ), តែពាក់អាវវែងកញ្ចាស់អង្គុយនៅកៀនជញ្ជាំង បរិភោគនូវដំឡូង ៗ

ពួកមនុស្សនៅប្រទេសនេះ ពេញចិត្តឲ្យគេបញ្ជោរ, អួតអាងហួសមាឌ, ហើយពិតមែនតែមើលទ្រង់ទ្រាយក្រៅជាមនុស្សប្រាជ្ញ, តែមិនមានគំនិតយល់ឃើញអ្វីឡើយ ។ ចរិយាសុទ្ធតែមានសភាពបន្ទំ ហើយបើមិនមានការគំរាមអ្នកដទៃទេ ច្រើនស្លៀកពាក់ខោអាវចាស់រហែក ៗ ជួនកាលមានខ្លះមកសួរលោកក៉ាស៊ូប៊ីយូយេ, ក្អកគ្រហែមរួចពោលថា: "ពីម្សិលមិញ ខ្ញុំបានទៅសន្និបាតពួកកវី, ដល់ខ្ញុំត្រឡប់មកគេហដ្ឋានវិញ

គឺពេលយប់យូរ ហើយខ្ញុំមានចិត្តសប្បាយពន់ពេកដោយឃើញព្រះច័ន្ទពេញបូណ៌មីត្រចះត្រចង់លើនភាល័យ" ។

មានខ្លះទៀតមកដល់ពោលថា: "ខ្ញុំបានចេញពីយប់មិញហើយខ្ញុំរីកពយសប្បាយចិត្តជាពន្លឹក ដោយបានទស្សនានូវព្រះចន្ទនឹងបុប្ផាទាំងឡាយ" ។ ការដែលសន្ទនានៃមនុស្សក្នុងប្រទេសនេះ សុទ្ធតែប្រកបដោយខត្តិភាព ។

ពេលព្រឹក, មានព្រិលធ្លាក់ពាសពេញដីក្រាស់ហើយ អាកាសត្រជាក់រងាខ្លាំង ។ លោកកាំសូប៉ីយូយេ បានឮអ្នកម្ចាស់ផ្ទះត្អូញត្អែរអំពីពេលអាក្រក់នេះ ហើយព្រួយចិត្តដោយគ្មានស្បៀងអាហារគ្រប់គ្រាន់នឹងភ្ញៀង, ព្រមទាំងប្រាក់សម្រាប់ទៅយកខោអាវរងាពីអ្នកបង្ក្រាប ។ ពួកនេះញាប់ខ្លួនចំប្រែប ព្រោះខ្លាចក្រែងស្លាប់ដោយរងាឬទុព្ភិក្ខភ័យ បើសិនណាជាពេលរងានេះ ស្ថិតនៅអស់រយៈវេលាបីថ្ងៃតទៅមុខទៀត ។ ពួកទាំងនេះ កំពុងតែគិតព្រួយពីជោគវាសនារបស់ខ្លួន ស្រាប់តែមានអ្នកជិតខាងម្នាក់ហៅទៅមើលព្រិលធ្លាក់, ពិតមែនតែទៅក្នុងហទយវត្ថុអ្នកទាំងអស់នោះដូចជារូបនិមិត្ត តែក្នុងចិត្តខ្លួន ក៏ពេញទៅដោយកាព្យឃ្លោងពីពេះមិនអាចនឹងទទួលទុក្ខលំបាក ដោយស្ថិតនៅក្នុងគេហដ្ឋានដោយមិនមកជួយលែកនូវសេចក្តីសប្បាយរបស់មិត្តក្នុងរឿងនេះ ។ ការពោលពាក្យកុហកជាទំនៀមអ្នកនៅប្រទេសនេះឥតមានសេចក្តីខ្មាសអៀន

ភ្ញីសោះឡើយ ។ អ្នកដែលរងទុក្ខលំបាកនោះដោយអាកាសត្រជាក់ញ័រអស់ទាំងអវយវៈសព្វសព៌ាង្គកាយ ។ អ្នកម្ចាស់ផ្ទះខំពាក់អាវវែងតាស់រត់ទៅខាងទ្វារហើយស្រែកថា: "ល្អហើយអ្នក" ។ ខ្ញុំបានក្រោកពីព្រលឹមដើម្បីនឹងទៅទស្សនានៅព្រិលដែលធ្លាក់ល្អអស្ចារ្យ ។ ដូចជាអ្នកកវីចិនពោលថា: "រុក្ខជាតិនិងតិណជាតិសើចញញឹមស្រស់និងព្រិល មុននិទាឃៈរដូវ" ឬដូចកវីជប៉ុនពោលថា "ព្រះចន្ទក៏បាំងថែងឥឡូវនេះនៅលើព្រិលដែលធ្លាក់ចុះបន្តិចម្តងៗ ស្ងាត់ស្ងៀមដូចសន្ទឹកបុប្ផា" ។ ខ្ញុំខ្លាចក្រែងព្រិលនោះ ត្រឡប់ទៅជាភ្លៀងវិញ តែខ្ញុំសង្ឃឹមថាទស្សនិយភាពដ៏ល្អជាពន្ទឹកនេះ មុខជានឹងមានមកច្រើនថ្ងៃ ក្នុងកាលជាអនាគត" ។ ពួកទាំងនោះបបូរមាតស្វាយដោយរដូវរងាចំប្រេប់អស់អង្គ, តែមានចិត្តគិតរក្សាទុកនូវការល្បីល្បាញខាងមនុស្សទៅតាមចរិតសព្វៗ ខ្លួន ៗ ក្នុងពេលនោះទាសីនៃអ្នកជិតខាងមកឲ្យដំណឹងអ្នកម្ចាស់ផ្ទះថា មានជាងមាសអញ្ជើញលោកទៅកាន់ពិធីថ្វៃង អត្តក្កង្រនកថា (Cérémonies d'encens) ហើយគេបានផ្ញើនូវគជខ្យងនឹងផ្កាប្មមកជូនលោកពិនិត្យ ។

(មានត)

ដំណើរតាមខ្យល់ក្នុងកណ្តារៈ

# លោក ផេង-ជ្រីវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

— រស្មីមសួរតបភ្លាមថាៈ តើព្រោះហេតុអ្វី? ឯងប្រាកដជានឹកស្មានថាយើងពល់គ្នាក្តីក្តើដូចជាពស់សំឡាប់កង្កែប ដែលដេកនៅកណ្តាលថ្ងៃឬ? ។

— អ៊ីស្មាអ៊ីលញញឹមចំអកឡើងហើយឆ្លើយថាៈ មិនមែនដូច្នោះទេ សំឡាញ់! ចុះក្រែងឯងឬ ដែលបាននិយាយអម្បាញ់មិញ តក៏ថា រឿងអស់នេះត្រូវហាមផ្តាច់មិនឲ្យនិយាយ? មិនតែប៉ុណ្ណោះ ថែមទាំងមានទោសដល់អ្នកនិយាយនឹងដល់អ្នកស្តាប់ទៀត ។

— រស្មីមដើរសំដៅអ៊ីស្មាអ៊ីល យកដៃទះស្មាដោយសេចក្តីស្និទ្ធស្នាលហើយនិយាយថាៈ ល្អហើយ! ល្អហើយ! រក្សាការណ៍សម្ងាត់ឯងទុកចុះ ។

— មួយស្របក់ រស្មីមលោដើរថយក្រោយក្រាកៗ ហើយស្រែកសើចចំអកថាៈ ហា! ហា! ធុំក្លិនទឹកអប់ណាស់! អីនៅអឺរុប ឯងរៀនអប់ខ្លួនឲ្យក្រអូបដូចជាស្រីឬ? ។

បើចង់ឲ្យយល់ថាពាក្យទាំងប៉ុន្មាន ដែលរស្មីមហាទេគឹម នសេចក្ដីប្រមាថដល់អ៊ីស្មាអ៊ីល ត្រូវឲ្យដឹងប្រវត្តិជាតិអាក់ប ទាំងត្រូវស្គាល់ឲ្យច្បាស់ថាក្នុងប្រទេសអាក់ប៉េគេទុកស្រីជាជាកេទគន់ថយដូចម្ដេចសិន ។

ដោយមានសេចក្ដីគោរពដល់ឪពុកដែលជាមិត្តចិត្តស្មោះត្រង់នឹងឪពុករស្មីម ម្យ៉ាងទៀត ដោយមានការរក្សានូវច្បាប់ប៉ាហុណេយ្យវត្ត ទើបអ៊ីស្មាអ៊ីលមិនតបតជាសេចក្ដីមើលងាយទៅវិញ គ្រាន់តែនិយាយដោយសំដីមធ្យតថា:

– នៅប្រទេសអឺរ៉ុប ខ្ញុំបានស្គាល់មនុស្សខ្លាំងពូកែជាច្រើនដែលចេះស្ទូវដែកនឹងចេះត្រួតសង្កត់លើមហាសាគរបាន ។

ហើយពេលនោះ អ៊ីស្មាអ៊ីល គាំងរៀបរាប់អំពីរបស់ដែលគេបានឃើញ គឺឡានឹងកេង់ចក្រស្ទូវដែកដែលក្នុងព្រៃនៃគិម្ហរដូវបាំងពន្លឺក្រហមព្រាលទៅលើមេឃជីវភាពគួរស្ញប់ស្ញែងនៅក្រោមប្រថពី តាមរូងជំងងឹតឈើងរបស់អ្នកយកធ្យូងថ្ម ចំការស្រាសាលីនឹងចំការទំពាំងបាយជូរយ៉ាងធំធ្លាយទូលាយ ដែលរដូវប្រមូលមានមនុស្សទាំងទ័ពកាន់ខ្នែវមួយម្នាក់នៅដៃនាំគ្នាច្រូតកាត់គ្រឹកគគ្រេង មិនតែប៉ុណ្ណោះ អ៊ីស្មាអ៊ីលអធិប្បាយអំពីរថភ្លើងដែលទាញទូរច្រើនអនេកបរតាមផ្លូវដែកគួរឲ្យកោតគំនិតប្រាជ្ញានៃជនអ្នកកសាង ព្រោះថាបើលោតែស្ពឺណាមួយវិលមិនត្រង់គ្នានឹងអាចឲ្យសេចក្ដីស្លាប់ដល់មនុស្សរាប់រយ រាប់ពាន់ជាប្រាកដ ៗ គេប្រាប់អំពី

ចិត្តក្លាហាននៃតែកុងយន្តហោះ ដែលប្រថុយជីវិតទាំងមុខស្រស់ញញឹម គេថ្លែងអំពីរបស់ដែលបានឃើញក្នុងដំណើរទាំងអស់ តាំងពីវាលស្មៅ វាលចំការរហូតដល់រោងចក្រក្រហាមរន្ទាលដែលគេបង្ហូរដែក ដំដែកប្រែត្រឡប់ហើយបង្កើតបានជានាវាយ៉ាងសម្បើមអស្ចារ្យ ដែលជាកិត្តិយសដ៏ឧត្តុង្គឧត្តមរបស់ជាតិ ។

ម្យ៉ាងទៀត ប្រវត្តិប្រទេសមិនទៅកើលគ្នាតែត្រឹមវិជ្ជាហត្ថកម្មដ៏ខ្លាំងពូកែប៉ុណ្ណោះទេ អ៊ីស្មាអ៊ីល ពោលប្រាប់ថែមទៀតអំពីការប្រឹងប្រែងនៃអ្នកប្រាជ្ញទាំងឡាយ ទាំងអ្នកប្រាជ្ញខាងទស្សនវិជ្ជា អំពីកិច្ចការនៃកវីបណ្ឌិត អំពីផលប្រយោជន៍នៃជាងខាងរចនាការ គឺអ្នកទាំងអស់នេះហើយ ដែលជាកិត្តិយស ដែលជាសេចក្ដីរុងរឿងរបស់ប្រទេស ។ រួចអ៊ីស្មាអ៊ីល ក្រោកឡើង និយាយសេចក្ដីដោយពាក្យយ៉ាងខ្លី ហើយដាច់ត្រឹមថា៖

- ហ្នឹងហើយរបស់ដែលខ្ញុំបានឃើញ! ខ្ញុំមានសេចក្ដីស្ដាយណាស់ ដោយជនជាតិប្រទេសខ្ញុំគិតតែនាំគ្នាបឺតខ្សៀរទឹកក្រអូប មិនគិតខំកសាងមាតុភូមិទុកជាប្រយោជន៍ទៅអនាគត ។ មនុស្សម្នាក់ៗ តាំងពីក្មេងដល់ចាស់គិតតែប្រមូលស្រីៗ មកធ្វើជាអស់អ្នកអស់នាង ហើយជីវភាពម្នាក់អស់ហើយតែត្រឹមដេកខ្ជិល ពេញចិត្តតែនឹងត្រណាប់ផ្លែឈើតាំងពីព្រលឹមទល់ព្រលប់ ហើយនឹងផឹកទឹកបានៈត្រជាក់ស្ងួម ។ អ៊ីស្មាអ៊ីល និយាយតែប៉ុណ្ណោះហើយក៏ឈប់ស្ងៀម ។

រស្មីមេបនអាប់ដាឡូស់បែរមុខទៅរកលោកអែយ៉ាដ ។

លោកអែយ៉ាដអ៊ីតមិនថា ដក់តែខ្សឹកក្រអូបផ្លូមិនដឹងក្រុក រលីវៗ ។ ពិតមែនតែលោកមិនបញ្ចេញអាការឲ្យស្គាល់ តែខាងក្នុងលោកកំណត់ទុកក្នុងដួងចិត្ត ដោយដាច់ស្រេចថាកូនប្រុសរបស់លោកបែកគំនិតបន្តិចម្តងៗរាល់ថ្ងៃ ឃ្លាតចាកគំនិតរបស់លោកកែលជាគំនិតត្រឹមត្រូវបញ្ចូនបន្តគ្នាទុកជាកេរ្តិ៍ពីដូនតាដល់កូន ។

ចំណែកពួកភ្ញៀវលោកអែយ៉ាដបែបភ្ញាក់ខ្លួនព្រើតរាល់គ្នា ដ្បិតទើបតែម្តងនេះជាដំបូងបំផុតដែលអ៊ីស្មាអ៊ីល លោភ្លាយច្បាប់គំនិតដែលគេយល់ដោយការដាច់ខាត ។

ក្នុងឱកាសនេះ រស្មីមដឹងជាក់ថា ពួកភ្ញៀវមិនយល់តាមគំនិតអ៊ីស្មាអ៊ីលទាំងអស់ ហើយដោយសេចក្តីប្រកាន់ពួក ទើបនិយាយម្តងទៀតដោយសំដីលាយឡំនឹងសេចក្តីប្រមាថផងព្រមទាំងការបំអកផងថា:

— អ៊ីស្មាអ៊ីល! ឥឡូវអញស្តាប់បានថាឯងមិនបានធ្វើពេលវេលាឲ្យខូចខាតសោះ ក្នុងសម័យដែលឯងបានទៅអាស្រ័យនៅប្រទេសអឺរ៉ុបគឺថាឯងបានជាអ្នកបេះមួយព្រមទាំងចិត្តថ្មើមក៏សប្បុរសផង ។ បើដូច្នេះឯងត្រូវអានក្បួនថ្មីរបស់ឯងពីរបីគាថាឲ្យយើងស្តាប់ផងមើល! ។

អ៊ីស្មាអ៊ីលឆ្លើយតបដោយសំដីដ៏ធ្ងន់ថា:

- កុំនិយាយលេង រស្មី ! មនុស្សក្នុងប្រទេសអ៊ីរុបមានចិត្តសប្បុរសទីងប្រកបដោយច្បាប់ជាជាងជន ដែលជាទីគោរពរបស់យើងទៅទៀត ។ នៅប្រទេសអ៊ីរុបមនុស្សទាំងអស់សុទ្ធតែមានសេរីភាព បំណែកស័ក្តិយសគេតម្រូវទៅតាមអំពើនីងមារយាទល្អនៃជនម្នាក់ៗ គឺមិនមែននិយមគោត្រត្រកូលទីងធនធានឡើយ ។ គេមិនមែនចិញ្ចឹមអ្នកក្រខ្សត់ដើម្បីបន្ទាបបន្ថោកនីងធ្វើទុកបុកម្នេញដូចជាសត្វបំរើទេ ។ អ្នកមានស័ក្តិខ្ពង់ខ្ពស់មិនត្រូវការតម្រូវចិត្តខ្លួនដោយការណ៍បន្ទាប់បន្ទំ ដើម្បីសំដែងឲ្យគេដឹងថាខ្លួនមានអំណាចទេ បំណែកត្រង់អំពើនិងចិត្តវិញ គេមិនបង់ធ្វើអ្នកជិតខាងឲ្យដល់នូវសេចក្តីវិនាសឡើយ ។ នៅប្រទេសអ៊ីរុបមនុស្សទាំងអស់ទុកគ្នាជាបងប្អូន ហើយពាក្យថាសាមគ្គីធម៌មិនមែនជាសំដីឥតការណ៍ឡើយ ។ នៃរស្មី ! ចូរឯងជឿអញ មនុស្សក្នុងអ៊ីរុបច្រើនមានសេចក្តីក្លាហានជាងយើង ហើយគេក៏ត្រូវការទីងកេរ្តិ៍ឈ្មោះដូចយើងដែរ ។

- រស្មីស្រែកឡើងទាំងកំហឹងថា: យើ ! អីនៅមុខយើង ឯងហ៊ានសរសើរជនជាតិអ៊ីរុប? ។

- អ៊ីស្មាអ៊ីលក្រោកឡើងហើយនិយាយថា: ជនជាតិអ៊ីរុបប្រាកដជាមានដំឡៃជាងយើង ។ (មានត)

# សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## បរិយាយពីវិធាននៃក្រុមជំនុំ

### ក្នុងឆមាសទី ២ ឆ្នាំ ១៩៥៣

លោក ជាប - ពិន រៀបរៀង

---

ខ្ញុំសូមបរិយាយអំពីវិធានការនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ចំពោះឆមាសទី ២ ឆ្នាំ ១៩៥៣ ប្រកាសនាមសមាជិកឆ្លើយឆ្លង និងបេក្ខជន ដែលបានសរសេរឯកសារទំនៀមទម្លាប់ខ្មែរ មកឲ្យការ និង មកប្រឡង ដូចតទៅនេះ ៖

១.– អំពីលទ្ធផលនៃការប្រឡង

ក្នុងឆមាសទី ២ នៃឆ្នាំ ១៩៥៣ ក្រុមជំនុំបានបើកឱកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ ២ រឿង គឺរឿងហោកសាស្ត្រ និងរឿងទឹក ៗ ក្រុមជំនុំបានទទួលឯកសារសម្រាប់ប្រឡងនេះ ២០ រឿង អំពីបេក្ខជន ១២ រូប ដែលស្ម័គ្រប្រឡង, បានជួបជុំពិនិត្យឯកសារទាំងនោះដោយហ្មត់ចត់ ឃើញបានលទ្ធផលដូចរៀបរាប់ខាងមុខនេះ ៖

ក) រឿងហោកសាស្ត្របានជាប់ ២ រូប គឺ

– រង្វាន់លេខ ៣ រឿងហោកសាស្ត្រ ត្រូវបាន ២០០រ,០០ ដល់លោក រ័ត្ន - ផូរ នៅផ្សារស្វាយរៀង ស្រុករំដួល (ស្វាយរៀង);

- រង្វាន់លេខ ៤ រឿងហោរាសាស្ត្រ ត្រូវបាន ១០០៛,០០ ដល់លោក ឌ្វីង ភ្លៅ នៅភូមិពោធិ៍ចុស (សៀមរាប) ។

១) រឿងទឹក បានជាប់ ៤ រូប គឺ

- រង្វាន់លេខ ២ រឿងទឹក ត្រូវបាន ៣០០៛,០០ ដល់ព្រះមហា ឈឹម-ផន និស្សិតឆ្នាំទី ៣ (១) នៃសាលាបាលីជាន់ខ្ពស់ ភ្នំពេញ;

- រង្វាន់លេខ ៣ រឿងទឹក ត្រូវបាន ២០០៛,០០ ដល់លោកគ្រូ មៀន-សុវណ្ណជោតិ វត្តសំរោង (បាត់ដំបង);

- រង្វាន់លេខ ៤ រឿងទឹក ត្រូវបាន ១០០៛ ០០ ដល់លោកប្រាក់-ខាត់ នៅឃុំពង្រ ស្រុកឆ្លូង (ក្រចេះ);

- រង្វាន់លេខ ៤ រឿងទឹក ត្រូវបាន ១០០៛,០០ ដល់លោកគ្រូ សុខ-លាក វត្តខ្ពុំ ស្រុកពារាំង (ព្រៃវែង) ។

២.- អំពីឈ្មោះសមាជិក និងឯកសារ

ឈ្មោះសមាជិកឆ្លើយឆ្លង និងឯកសារដែលក្រុមជំនុំបានទទួលក្នុងឆមាសទី ២ ឆ្នាំ ១៩៥៣ ដូចរៀបរាប់តទៅនេះ គឺ

- លោក ខៀ-វ៉ាន់ ឃុំក្កុង ស្រុកបន្ទាយមាស (កំពត) បានឲ្យការ ៧ រឿង គឺរឿងចំណីអាហារ, រឿងប្រវត្តិភូមិខ្មែរ, សាវតារខ្មែរ, ប្រវត្តិក្រុង, រឿងឆ្លងទន្លេ, រឿងហោរាសាស្ត្រ និងរឿងទឹក;

- លោក ទេព-រស់ ឃុំលំចង់ ស្រុកសំរោង (តាកែវ) បានឲ្យការ ៣ រឿង គឺរឿងហោរាសាស្ត្រ, រឿងទឹក និងរឿងព្រេង;

- លោក ប៊ុន-ប៉ូរ ប៉ូលិសស្រុកជាំក្សាន្ត (កំពង់ធំ) បានឲ្យការ ២ រឿង គឺរឿងហោកសាស្ត្រ និងរឿងទឹក;

- លោក ហោ-ជឹម ឃុំកំពង់ពពិល ស្រុកពារាំង (ព្រៃវែង), បានឲ្យការ ២ រឿង គឺរឿងផ្កាយកូនមាន់ និងរឿងទឹក;

- លោក ឌួង-អ៊ូច មេឃុំអង្កាញ់ ស្រុកព្រៃកប្បាស (តាកែវ) បានឲ្យការ ១ រឿង គឺរឿងហោកសាស្ត្រ;

- លោក កែវ-ហង្ស ចាងហ្វាងរ៉ូត្រែត ឃុំសួង ស្រុកត្បូងឃ្មុំ (កំពង់ចាម) បានឲ្យការ ២ រឿង គឺរឿងហោកសាស្ត្រ និងរឿងទឹក;

- លោក ធូរ-អ៊ុក ប៉ុស្តិ៍តុងសាលាខេត្ត (តាកែវ) បានឲ្យការ ២ រឿង គឺរឿងហោកសាស្ត្រ និងរឿងទឹក;

- លោក គង់-ចន្ទនៈ ឃុំដៃរឿន ស្រុកព្រៃឈរ (កំពង់ចាម) បានឲ្យការ ៤ រឿង គឺរឿងហោកសាស្ត្រ, រឿងទឹក, រឿងក្លាប ពាក្យស៊ីស្វា និងរឿងព្រេង ។

* * *

នៅប្រទេសកម្ពុជាយើង ណាជនដែលចេះចាំទំនៀមទម្លាប់ខ្មែរ មានច្រើនជាអនេក មិនមែនតិចទេ, ប៉ុន្តែដែលនឹងសរសេរតែងឯកសាររឿងទំនៀមទម្លាប់ខ្មែរផ្សេងៗ ឲ្យការមកក្រុមជំនុំទំនៀមទម្លាប់ខ្មែរបាននោះ លុះតែចេះចាំទំនៀមទម្លាប់ផ្សេងៗផង, យល់ច្បាស់ថា ឯកសារ

ទំនៀមទម្លាប់ខ្មែរជាគោលចារិកដ៏សំខាន់សម្រាប់ប្រទេសជាតិផង, ចង់ឲ្យអារ្យធម៌ខ្មែរឋិតថេរគង់វង្សទៅក្នុងអនាគតផង ទើបអាចកាត់សេចក្ដីរល់ត្មៀតនុកាសសារសោរតែងឯកសារផ្សេងៗ នោះៗ មកឲ្យការដល់ក្រុមជំនុំទំនៀមទំម្លាប់បាន, បើមិនយកចិត្តទុកដាក់មិនអាចធ្វើបានទេ; ព្រោះហេតុនេះបានជា ក្រុមជំនុំទំនៀមទម្លាប់ខ្មែរដែលបានទទួលឯកសារទៀនទំនៀមផ្សេងៗ អំពីអស់លោកជាសមាជិកឆ្លើយឆ្លង ទីងជាបេក្ខជនដែលបានយកចិត្តទុកដាក់សារសោរតែងឲ្យការមក ទីងមកប្រឡងនោះហើយមានអំណរក្រៃពេក, សូមប្រកាសសេចក្ដីសរសើរជាឧឡារិក ដ៏ស្មោះត្រង់ចំពោះអស់លោកទាំងនោះ ដែលបានត្មៀតនុកាសសារសោរតែងឯកសារទំនៀមទម្លាប់មានប្រការផ្សេងៗ មកឲ្យការដល់ក្រុមជំនុំទីងមកប្រឡងចំពោះឆមាសទី ២ ឆ្នាំ ១៩៥៣ ដូចពាយនាម ទីងឯកសារពីខាងលើនេះ ។

សូមអស់លោកសមាជិកឆ្លើយឆ្លង ទីងបេក្ខជនទាំងឡាយ ដែលធ្លាប់ឲ្យការមកបុធ្លាប់ប្រឡងហើយក្ដី អស់លោកវិញ្ញូជនរួមជាតិទាំងឡាយដែលមិនទាន់ធ្លាប់ក្ដី ចំត្មៀតសារសោរតែងឯកសារផ្សេងៗ ដែលទាក់ទងដោយទំនៀមទម្លាប់ខ្មែរ ជាការជួយឧបត្ថម្ភកិច្ចការរបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរឲ្យចម្រើនជាកិយោភាគ ដើម្បីឲ្យអារ្យធម៌ខ្មែរគង់នៅជាមត៌ករបស់ជាតិតទៅ ។

ក្រុមជំនុំសូមទទួលអំណរគុណ យ៉ាងខ្ពស់ទុកជាមុន ។

---

# សមណស័ក្តិនៃព្រះសង្ឃ ១៣ រូប

## ពុទ្ធសាសនបណ្ឌិត្យ

---

តាមបញ្ញត្តិក្នុងព្រះរាជក្រមលេខ ១២ ន ស. ចុះថ្ងៃទី ៩ កុម្ភៈ ១៩៤៣ ដោយសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយថ្វាយព្រះពរសូម, ដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ ក៏បានយល់ព្រមផង ហើយបានក្រាបបង្គំទូលថ្វាយ, ព្រះករុណាជាម្ចាស់ជីវិតលើត្បូងព្រះប្រិយមហាក្សត្រិយ៍ ជាអគ្គពុទ្ធសាសនូបត្ថម្ភក: ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានតាំងព្រះថេរៈទាំងឡាយ ១៣ អង្គ ឲ្យឡើងសមណ-ស័ក្តិទីព្រះរាជាគណៈតាមលំដាប់ថ្នាក់ ឯក - ទោ - ត្រី - បត្វា ដោយព្រះរាជក្រិត្យលេខ ៥ ប.រ. ចុះថ្ងៃទី ២១ មករា ១៩៥៦ ដូចមានរាយនាមនឹងសមណស័ក្តិតទៅនេះ គឺ:

១ – ព្រះមុនីកោសល អ៊ុំ-ទួត មេគណខេត្តបាត់ដំបង រាជាគណៈថ្នាក់ទោ ឡើងជា ព្រះវនរ័ត ថ្នាក់ឯក ជាជំនួសព្រះវនរ័ត ពេជ្រ-មឿង វត្តឧណ្ណាលោម ដែលទទួលអនិច្ចធម្ម ។

២ ព្រះពុទ្ធវង្ស សោម-ឈុន មេគណខេត្តកណ្តាល រាជាគណៈថ្នាក់ត្រី ឡើងជា ព្រះមុនីកោសល ថ្នាក់ទោ ។

៣ – ព្រះញាណវង្ស កៅ-នេត្រ វត្តឧណ្ណាលោម រាជាគណៈថ្នាក់ត្រី ឡើងជា ព្រះមហាវិមលធម្ម ថ្នាក់ទោ (ដែលនៅទំនេរតាំង

ពីព្រះមហាវិមលធម្ម ហួត-តាត ឡើងជាព្រះពោធិវង្ស ពជាគណៈថ្នាក់ឯក) ។

៤ – ព្រះឧបាលិវង្ស ម៉ឺង-សែស ពជាគណៈថ្នាក់ត្រី ចៅអធិការវត្តមហាមន្ត្រីក្រុងភ្នំពេញ ឡើងជា ព្រះឃោសធម្ម ថ្នាក់ទោ ជាជំនួសព្រះឃោសធម្ម ហ៊ីន-ម៉ៃ វត្តឧណ្ណាលោមដែលទទួលអនិច្ចធម្ម ។

៥ – ព្រះវិកទញ្ញាណ កៅ-ស៊ុម វត្តលង្កា ពជាគណៈថ្នាក់ចត្វា ឡើងជា ព្រះពុទ្ធវង្ស ថ្នាក់ត្រី ។

៦ - ព្រះសមាធិធម្ម អ៊ួ-ស្សូរ វត្តសារាវ័ន ពជាគណៈថ្នាក់ចត្វា ឡើងជា ព្រះញាណវង្ស ថ្នាក់ត្រី ។

៧ – ព្រះទេពសត្ថា ស្សូរ-ហាយ វត្តឧណ្ណាលោម ពជាគណៈថ្នាក់ចត្វា ឡើងជា ព្រះឧបាលិវង្ស ថ្នាក់ត្រី ។

៨ – ព្រះគ្រូញាណកេសរ ស្វាយ-អ៊ឹម ទីឋានានុក្រម ចៅអធិការវត្តសំពៅមាស ឡើងជា ព្រះសមាធិធម្ម ពជាគណៈថ្នាក់ចត្វា ។

៩ – ព្រះគ្រូបញ្ញាវិទូ ឡុង-បាង ទីឋានានុក្រម ចៅអធិការវត្តកែវព្រះភ្លើង ក្រុងភ្នំពេញឡើងជា ព្រះវិកទញ្ញាណ ពជាគណៈថ្នាក់ចត្វា ។

១០ – ព្រះគ្រូសិរីសោភ័ណ កឹម-គ្យូរ ទីឋានានុក្រម វត្តឧណ្ណាលោម ឡើងជា ព្រះទេពសត្ថា ពជាគណៈថ្នាក់ចត្វា ។

១១ – ព្រះគ្រូសាសនមុនី អ៊ុន-ឡាប ទីឋានានុក្រម ចៅអធិការវត្តកោះ ឡើងជា ព្រះសិរិសង្គាមមុនី រាជាគណៈ ថ្នាក់ចត្វា ជាជំនួសព្រះសង្គាមមុនី ជុប-រស់ ដែលទទួលអនិច្ចធម្ម ។

១២ – ព្រះគ្រូវិសុទ្ធិមុនី ប្រាជ្ញ-ប៉ុល ទីឋានានុក្រម វត្តខ្ណាលោម ឡើងជា ព្រះទេពមុនី រាជាគណៈថ្នាក់ចត្វា ជាជំនួសព្រះទេពមុនី យូរ-ប៉ុណ្ណ វត្តខ្ណាលោម ដែលទទួលអនិច្ចធម្ម ។

១៣ – ព្រះធម្មានុសិដ្ឋិសាទរ ញ៉ឹក-ជា ទីឋានានុក្រម ចៅអធិការវត្តសោមនស្ស ខែត្របាត់ដំបង ឡើងជា ព្រះញាណសំវរ រាជាគណៈ ថ្នាក់ចត្វា ជាជំនួសព្រះញាណសំវរ ទុម-ឯក អនុគណ ស្រុកបាត់ដំបង ដែលទទួលអនិច្ចធម្ម ហើយបានឡើងជាអនុគណ ស្រុកបាត់ដំបងតាមដំណែលមុន ។

យើងសូមប្រគេនសាធុការពរចំពោះព្រះថេរ ទាំង ១៣ អង្គ ដែលទើបបានឡើងសមណស័ក្តិ ៗ នេះ សូមបានប្រកបដោយពរគឺ អាយុ: វណ្ណ: សុខ: ពល: និងវឌ្ឍនភាពក្នុងព្រះពុទ្ធសាសនាតអង្វែងទៅ ។

ពុទ្ធសាសនបណ្ឌិត្យ